# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2019, 14:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើរបស់លោក ខៀវ សំផន សុំថ្លែងជំទាស់ចៅក្រម ៦ រូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចសេចក្ដី នៅក្នុងសំណុំរឿង ០០២/០២**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន៖**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Cécile ROUBEIX
កញ្ញា Dounia HATTABI
កញ្ញា Marine BOUDJEMAA
លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ រួចត្រូវបានបញ្ជូនទៅជំនុំជម្រះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១[1]។

២. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានបំបែកបទចោទដោយបានចេញដីកាសម្រេចលើកទីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី[2] ដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ធ្វើមោឃភាព ("សេចក្តីសម្រេចលើកទីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")[3]។ តុលាការកំពូលបានតម្កល់ដីកាសម្រេចលើកទីពីរ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")[4]។ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងត្រូវបានតុលាការកំពូលតម្កល់ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ("សេចក្តីសម្រេច

---

[1] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ **D427** ("ដីកាដំណោះស្រាយ **D427**") កថាខណ្ឌ ១៦១៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/2/12** និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/4/14**។

[2] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E124**។

[3] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ **E163/5/1/1/3** ("សេចក្តីសម្រេចលើកទី១លើការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/1/3**")។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ - សេចក្តីសង្ខេបនៃសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E284/4/7** ។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E284/4/8** ( "សេចក្តីសម្រេចលើកទី២លើការបំបែកកិច្ចដំណើរការនីតិវិធី - សំអាងហេតុ **284/4/8**")។

លើកទីបីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")[5] ដោយអនុញ្ញាតឲ្យជំនុំជម្រះក្តីពីរដង (សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២) ដែលមានអង្គហេតុ និងអង្គច្បាប់ជាប់ពាក់ព័ន្ធ និងត្រួតគ្នា។

៣. នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបានផ្តន្ទាទោសគាត់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត[6]។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ចៅក្រមតុលាការកំពូលទាំងអស់ លើកលែងតែ ចៅក្រម Maureen HARDING CLARK បានប្រកាសសាលដីកាប្រឆាំងនឹងសាលក្រមនេះ និង បានតម្កល់ការផ្តន្ទាទោស (សាលដីកាសំណុំរឿង ០០២/០១")[7]។

៤. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹង មនុស្សជាតិ និងបទបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយគ្មានផ្តល់សំអាងហេតុ[8]។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានស្នើ សុំតុលាការកំពូលឲ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ[9]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចបដិសេធបណ្តឹងសាទុក្ខនេះ ដោយមាន សមាសភាពរួមទាំងចៅក្រម Phillip RAPOZA ផងដែរ[10]។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩

---

[5] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E301/9/1/1/3** ("សេចក្តីសម្រេចលើកទី២លើការបំបែកកិច្ចដំណើរការនីតិវិធី **E301/9/1/1/3**")។

[6] សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E313**។

[7] សាលដីកា ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** ("សាលដីកា ០០២/០១ **F36**")។

[8] ប្រតិចារឹកសវនាការ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៦៤-៦៨ ម៉ោង ១១ និង ២៨នាទី និងម៉ោង ១១និង ៣៨នាទី ។

[9] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** ("បណ្តឹងសាទុក្ខភ្លាមៗ **E463/1**")។

[10] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែល បានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3** ("សេចក្តីសម្រេចលើបណ្តឹង សាទុក្ខភ្លាមៗ **E463/1/3**") កថាខណ្ឌ ១៨។

មេធាវីការពារក្តីបានស្នើសុំធ្វើមោឃភាពសេចក្តីសម្រេចនេះ ពីព្រោះពេលនោះ ក្រុមប្រឹក្សាចៅក្រមមានសមាសភាពមិនត្រឹមត្រូវ[11]។ សំណើនេះត្រូវបានជូនដំណឹង នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩[12] និងត្រូវបានតុលាការកំពូលប្រកាសថាគ្មានមូលដ្ឋាន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩[13]។

៥. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីបានទទួលការជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សំអាងហេតុនៃសាលក្រម")[14]។

៦. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តីបានចង្អុលបង្ហាញអំពីចេតនាដាក់បណ្តឹងជំទាស់ចិត្តចៅក្រមតុលាការកំពូល ("ចៅក្រមរងបណ្តឹងជំទាស់ចិត្ត") ក្នុងសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[15]។

៧. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដោយបានបញ្ជាក់អះអាងជាថ្មីម្តងទៀតអំពីចេតនាដាក់បណ្តឹងជំទាស់ចិត្ត ឱ្យបានឆាប់បំផុត[16]។ នៅថ្ងៃ

[11] សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៩ ឯកសារ **E463/1/4** ("សំណើសុំធ្វើមោឃភាព **E463/1/4**") ។

[12] សំណើសុំបានដាក់នៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៩ នៅម៉ោង ១១ និង៥២នាទី ហើយត្រូវបានរក្សាទុកជាសម្ងាត់ដោយមិនស្របច្បាប់រយៈពេលបីខែ។

[13] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ **E465/1/5** ("សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព **E465/1/5**")។

[14] សាលក្រម [សំណុំរឿង ០០២/០២] ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465**។

[15] សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1** ("សំណើពន្យារពេល F39/1.1") កថាខណ្ឌ ៣៥។

[16] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ **E465/4/1**") កថាខណ្ឌ ១៤។

ទី២៣ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[17]។

៨. តាមរយៈសារណានេះ មេធាវីការពារក្តីស្នើសុំប្តឹងជំទាស់ចៅក្រមតុលាការកំពូល ៦ រូប ដែលបានសម្រេចសេចក្តី ក្នុងសំណុំរឿង ០០២/០១។ សំណើអាចទទួលយកបាននេះ (១) ផ្អែកលើសិទ្ធិជាមូលដ្ឋាន និងដាច់ខាត ក្នុងការទទួលបានការកាត់ក្តីពីតុលាការអនាគតិ (២) ដែលត្រូវបានជាន់ឈ្លីដោយអត្ថិភាពនៃភាពលម្អៀង និងអាការៈនៃភាពអគតិ ដែលមិនអាចសម្រុះសម្រួលបានជាមួយមុខងារជាចៅក្រមតុលាការជាន់ខ្ពស់ (៣)។

## ១. ភាពអាចទទួលយកបាននៃសំណើនេះ

៩. យោងតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង បណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមតុលាការកំពូលត្រូវធ្វើឡើង "ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងមុនពេលធ្វើបណ្តឹងសាទុក្ខ នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ" និង "នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"[18]។ លើសពីនេះទៀត តុលាការកំពូលបានអះអាងថា លក្ខខណ្ឌ ដូចមានចែងនៅក្នុងវិធាន ៣៤៖

> "**ត្រូវតែមានបណ្តឹងសាទុក្ខភ្លាមៗដែលដាក់ដោយម្ចាស់បណ្តឹង ដែលកំពុងរង់ចាំសេចក្តីសម្រេច**ពីអង្គជំនុំជម្រះ នៅពេលដែលម្ចាស់បណ្តឹងដាក់បណ្តឹងជំទាស់របស់គាត់" ស្របតាមបទប្បញ្ញត្តិដែល "តម្រូវឱ្យម្ចាស់បណ្តឹង**មានផលប្រយោជន៍ផ្លូវច្បាប់ (មូលដ្ឋានសំខាន់ចាំបាច់នៃបណ្តឹង)** នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែលអាចត្រូវបានទទួលរងផលប៉ះពាល់ ប្រសិនបើអង្គជំនុំជម្រះពុំបានពិចារណាលើអង្គសេចក្តីនៃសំណើសុំជំទាស់"[19]។

---

[17] ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (សំណុំរឿង ០០២/០២) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ **F50/1**។

[18] វិធាន ៣៤.៤ ឃ និង ៣៤.៣ នៃវិធានផ្ទៃក្នុង។

[19] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម សោម សិរីវុឌ្ឍ ដោយសារពុំមានឯករាជ្យ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ 1/4 កថាខណ្ឌ ៤ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) ។

១០. សំណើត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ដោយ "ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភ័ស្ដុតាងបញ្ជាក់ផងដែរ"[20]។ បន្ទុកបង្ហាញភ័ស្ដុតាងត្រូវធ្លាក់លើភាគីម្ចាស់បណ្ដឹងដិតចិត្ត ហើយចៅក្រមត្រូវទទួលបានសច្ចធារណ៍អនាគតិខ្ពស់បំផុត[21]។

១១. សំណើនេះអាចទទួលយកបាន ពីព្រោះវាត្រូវបានដាក់ ក្នុងពេលរង់ចាំការសម្រេចលើបណ្ដឹងសាទុក្ខ នៅពេលចាប់ផ្ដើមនីតិវិធីបណ្ដឹងសាទុក្ខ[22]។ សំណើនេះផ្អែកជាមូលដ្ឋានលើវិសាលភាពនៃបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០២[23] ដែលកម្រិតត្រឹមតែកំហុសដែលភាគីបានលើកឡើង[24]។ សំណើនេះក៏ផ្អែកផងដែរលើភាពមិនត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី នាពេលថ្មីៗកន្លងទៅ[25]។ លើសពីនេះទៀត សំណើនេះផ្ដល់ជាលាយលក្ខណ៍អក្សរនូវសំអាងហេតុ និងភ័ស្ដុតាងដើម្បីគាំទ្រដល់ការចោទប្រកាន់អំពីភាពលម្អៀង។ ដូច្នេះ មេធាវីការពារក្ដីសូមលើកឡើង ជាអាទិ៍

---

[20] វិធាន ៣៤.៣ នៃវិធានផ្ទៃក្នុង។

[21] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១១២។ សូមមើលផងដែរ ៖ សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងដិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ **C11/29** ("សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **C11/29**") កថាខណ្ឌ ១៥, ១៦ និង ១៩ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤ ("ជើងទំព័រ") បានស្រង់សម្ដីពី *រឿងក្ដីតទល់រវាងរដ្ឋអាជ្ញា និង Furundzija* រឿងក្ដីលេខ IT-95-17-1/A សាលដីកា ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ("សាលដីកា Furundzija") កថាខណ្ឌ ១៩៦។ សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្ដឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ **E55/4** ("សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **E55/4**") កថាខណ្ឌ ១២។ សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម Silvia CARTWRIGHT ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ២០១២ ឯកសារ **E171/2** ("សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **E171/2**") កថាខណ្ឌ ១២។ សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង សារី សុំប្ដឹងដិតចិត្តលោកស្រីចៅក្រម Cartwright ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០១២ ឯកសារ**E191/2** ("សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **E191/2**") កថាខណ្ឌ ១៣។ សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងដឹតចិត្ត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ **E314/12/1** ("សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងដឹតចិត្ត **E314/12/1**") កថាខណ្ឌ ៣៥។

[22] បណ្ដឹងដិតចិត្តត្រូវបានព្យួរ ចាប់តាំងពីពេលដាក់សេចក្ដីជូនដំណឹងបណ្ដឹងដិតចិត្តចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ មក។ ម្យ៉ាងវិញទៀត សារណាបណ្ដឹងដិតចិត្តនៅមិនទាន់បានដាក់នៅឡើយសារណានោះត្រូវដាក់នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០) ។

[23] សូមមើលសំអាងហេតុដែលមានពង្រីកសេចក្ដីនៅខាងក្រោម ត្រង់ចំណុច III.ខ និង គ ។

[24] វិធាន ១០៦ នៃវិធានផ្ទៃក្នុង។

[25] សូមមើលអំណះអំណាងដែលមានពង្រីកសេចក្ដីនៅខាងក្រោម ត្រង់ចំណុច III.ឃ ។

នូវទំនាក់ទំនងរវាងសំអាងហេតុនៃសាលក្រមលើសំណុំរឿង ០០២/០២ សំអាងហេតុនៃសាលដីកាលើសំណុំរឿង ០០២/០១ និងផលប៉ះពាល់លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០២។ ឧបសម្ព័ន្ធទី ១ ដល់ ១៦ បង្ហាញអំពីទំហំនៃបញ្ហាដែលចៅក្រមរងបណ្ដឹងជិតចិត្តបានសម្រេចរួចមកហើយ។

## ២. <u>សិទ្ធិជាមូលដ្ឋានជាច់ខាតក្នុងការទទួលបានការកាត់ក្ដីពីតុលាការអនាគតិ</u>

១២. សិទ្ធិទទួលបានការកាត់ក្ដីពីតុលាការអនាគតិ ត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌគតិយុត្តិជាធរមាននៅចំពោះមុខ អ.វ.ត.ក ហើយការរំលោភលើសិទ្ធិនេះបណ្ដាលឲ្យមានការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។

១៣. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (“កិច្ចព្រមព្រៀង”) និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងដូចគ្នាថា ចៅក្រមត្រូវមាន “ចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត”[26]។ ចៅក្រមត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន៖

> “សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ”[27]។

១៤. មាត្រា ១៤(១) នៃកតិកាសញ្ញានេះចែងថា “ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ”។

១៥. វិធាននៃផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីត្រូវតែមានយុត្តិធម៌[28] និងកំណត់អំពីក្របខ័ណ្ឌគតិយុត្តិនៃបណ្ដឹងជិតចិត្តចៅក្រម ក្នុងវិធាន ៣៤ ដែលការពារដល់ជនជាប់ចោទ[29]។

---

[26] មាត្រា ៣.៣ នៃកិច្ចព្រមព្រៀង ។ មាត្រា ១០ នៃច្បាប់បង្កើត អ.វ.ត.ក។

[27] មាត្រា ១២.២ និង ១៣ នៃកិច្ចព្រមព្រៀង ។ មាត្រា ៣៣ និង ៣៧ នៃច្បាប់បង្កើត អ.វ.ត.ក។

១៦. មាត្រា ២ នៃក្រមសីលធម៌ចៅក្រមនៃ អ.វ.ត.ក ចែងថា "ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះ ក្នុងការបំពេញមុខនាទីរបស់ខ្លួន"។

១៧. យុត្តាធិការរបស់ អ.វ.ត.ក បានទទួលស្គាល់ថា "សិទ្ធិទទួលបាននូវតុលាការមួយឯករាជ្យ និងឥតលម្អៀង គឺជាធាតុ**សំខាន់**នៃសិទ្ធិជា**សារវ័ន្ត** ដើម្បីទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌"[30]។ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានអះអាងផងដែរថា "ការធានាបាននូវយុត្តាធិការ ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ ស្របតាមខ្លឹមសារនៃកថាខណ្ឌ ១ នៃមាត្រា ១៤ ជាសិទ្ធិ**ដាច់ខាត**ដោយគ្មាន**ការលើកលែង**"[31]។ អានុភាពដាច់ខាតនៃសិទ្ធិនេះត្រូវតម្រង់ទិសដល់ការវាយតម្លៃលើសំណើនេះ និងភ្ជាប់កាតព្វកិច្ចចៅក្រមក្នុងការវិនិច្ឆ័យលើអង្គច្បាប់ និងអង្គហេតុ[32]។

## ៣. <u>អត្ថិភាពនៃភាពលម្អៀងជាក់ស្តែង និងអាការៈនៃភាពអគតិមិនអាចទទួលយកបាន</u>

១៨. ការប្តឹងជំទាស់ចៅក្រមត្រូវតែធ្វើឡើង ដើម្បីធានាបាននូវសិទ្ធិជាមូលដ្ឋាន និងដាច់ខាតក្នុងការទទួលបានការកាត់ក្តីពីតុលាការអនាគតិ។

---

[28] វិធាន ២១.១-ក នៃវិធានផ្ទៃក្នុង។

[29] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ចៅក្រម លោកស្រីចៅក្រម Sylvia Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ **E137/5/1/3** កថាខណ្ឌ ១៥ ៖ "វិធាន ៣៤ នៃវិធានផ្ទៃក្នុង គឺជានីតិវិធីពិសេសមួយដែលមានគោលបំណងធានានូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសុចរិតភាពនៃតួនាទីតុលាការ"។

[30] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម **E5/3** កថាខណ្ឌ ៥ សូមមើលជើងទំព័រ ១៣ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[31] សេចក្តីសង្កេតទូទៅ លេខ ៣២ សិទ្ធិទទួលបានសមភាពចំពោះមុខតុលាការ និងការស្វែងរកយុត្តិធម៌និងការវិនិច្ឆ័យក្តីប្រកបដោយយុត្តិធម៌ គណៈកម្មាធិការសិទ្ធិមនុស្ស ឯកសាររបស់ អ.ស.ប ឯកសារ CCPR/C/GC/32 ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧ ("សេចក្តីសង្កេតទូទៅ លេខ៣២") កថាខណ្ឌ ១៩ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) ដែលដកស្រង់សម្តីពីរឿងក្តី *Gonzalez del Rio ទល់នឹងប្រទេសប៉េរូ* បទបង្ហាញលេខ ២៦៣/១៩៨៧ កថាខណ្ឌ ៥១។ យោងទៅ ៖ មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ១១ និង ជើងទំព័រ ២១។

[32] មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ២១។

១៩. លក្ខណៈវិនិច្ឆ័យគតិយុត្តិជាធរមានពាក់ព័ន្ធនឹងការប្ដឹងជំទាស់ដិតចិត្ត គឺជាលក្ខណៈវិនិច្ឆ័យនៃភាពលម្អៀងជាក់ស្ដែង និង/ឬអាការៈនៃភាពលម្អៀង ដែលមិនអាចទទួលយកបាន (៣.១)។ ក្នុងករណីនេះ មូលដ្ឋានរួមគ្នាបីច្រានចោលសច្ចធារណ៍អនាគតិខ្ពស់របស់ចៅក្រម។ សេចក្ដីសន្និដ្ឋាននៅក្នុងសាលដីកាលើសំណុំរឿង ០០២/០១ សម្រេចជាមុនលើមូលដ្ឋានបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ក្នុងសំណុំរឿង ០០២/០២ (៣.២)។ លើសពីនេះទៀត សេចក្ដីសន្និដ្ឋានខុសខ្លះនៃសាលដីកា (៣.៣) និងភាពមិនត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ចាប់តាំងពីពេលប្រកាសសាលក្រម (៣.៤) បង្ហាញអំពីអវត្តមាននៃភាពអនាគតិរបស់ចៅក្រមរងបណ្ដឹងដិតចិត្ត។

## ៣.១. <u>លក្ខណៈវិនិច្ឆ័យគតិយុត្តិដែលអនុវត្តចំពោះបណ្ដឹងដិតចិត្ត</u>

២០. វិធាន ៣៤(២) នៃវិធានផ្ទៃក្នុង កំណត់អំពីលក្ខណៈវិនិច្ឆ័យជាធរមាន ដោយចែងថា៖

> "ភាគីអាចធ្វើបណ្ដឹងដិតចិត្ត ចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង"[33]។

២១. វិធាននេះដាក់បញ្ចូលសញ្ញាណនៃភាពអគតិជាអត្តនោម័តិ (ភាពលម្អៀងជាក់ស្ដែង) និងភាពអគតិជាសត្យានុម័តិ (អាការៈនៃភាពលម្អៀង)[34] ស្របតាមបុរាណភាសិតមួយថា "តុលាការមិនត្រឹមតែរកយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវបង្ហាញឲ្យគេឃើញជាក់ស្ដែង និងដោយគ្មានមន្ទិលសង្ស័យនូវការស្វែងរកយុត្តិធម៌នោះផងដែរ"[35]។

---

[33] វិធាន ៣៤.២ នៃវិធានផ្ទៃក្នុង។

[34] សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **C11/29** កថាខណ្ឌ ១២។ សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម **E55/4** កថាខណ្ឌ ១១។ សេចក្ដីសង្កេតទូទៅ លេខ ៣២ កថាខណ្ឌ ២១។

[35] បុរាណភាសិតលើកឡើងដោយ Lord Hewart CJ នៅក្នុងសេចក្ដីសម្រេច *R. v Sussex Justices ex p McCarthy*, [1924] 1 KB 256 [1923] All E R 233 ដែលស្រង់សម្ដីជាភាសាបារាំងនៅក្នុង មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING ឯក

២២. យុត្តិសាស្ត្រខ្ជាប់ខ្ជួនរបស់ អ.វ.ត.ក បង្ហាញថា វិធាន ៣៤ ត្រូវបានបកស្រាយ ដោយផ្អែកលើលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ លក្ខខណ្ឌនេះមានដូចខាងក្រោម៖

> "ចៅក្រមមួយរូបមានភាពអគតិ ប្រសិនបើគេរកឃើញអត្ថិភាពនៃ**ភាពលម្អៀងជាក់ស្តែង**។ **អាការៈនៃភាពលម្អៀង**អាចកើតមាន ប្រសិនបើ៖
>
> - ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ហិរញ្ញវត្ថុ ឬលុយកាក់ ក្នុងរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះអាចលើកកម្ពស់បុព្វហេតុមួយ ដែលគាត់ជាប់ពាក់ព័ន្ធនឹងភាគីណាមួយក្នុងរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះត្រូវតែដកចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
> - កាលៈទេសៈបណ្តាលឲ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ អាចបារម្ភដោយសមហេតុផលថាមានភាពលម្អៀង"[36]។

២៣. ការបារម្ភដោយសមហេតុផលថាមានភាពអគតិត្រូវបានបង្ហាញ ទៅតាមទស្សនៈរបស់អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ ដែលជា៖

---

សារ

**E314/12/1** កថាខណ្ឌ ១២។

[36] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១១២ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ៖ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម ឯកសារ **C11/29** កថាខណ្ឌ ២០ ដែលស្រង់សម្តីពីសាលដីកា *Furundzija* កថាខណ្ឌ ១៨៩។ សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារ **E5/3** កថាខណ្ឌ ៦។ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ និង អៀង សារី ប្តឹងជំទាស់ចិត្តចៅក្រម យូរ ឧត្តរា ចេញពីអង្គចៅក្រមពិសេស និងសំណើសុំឲ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ **E63/5** កថាខណ្ឌ ១១។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម **E171/2**, កថាខណ្ឌ ១២។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម **E191/2** កថាខណ្ឌ ១៣ និង សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត **E314/12/1** កថាខណ្ឌ ៣៣។

"បុគ្គលម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់អំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងប្រពៃណីនៃសុចរិតភាព និងភាពអនាគតិ ហើយយល់ថា អនាគតិគឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចដទៃទៀត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់"[37]។

## ៣.២. អត្ថិភាពនៃភាពលម្អៀង នៅក្នុងសាលដីកាលើសំណុំរឿង ០០២/០១ ដែលសម្រេចជាមុនលើបណ្ដឹងសាទុក្ខលើសំណុំរឿង ០០២/០២

២៤. យោងតាមយុត្តិសាស្ត្រពាក់ព័ន្ធ (៣.២.១) ច្បាស់ណាស់ថាហេតុផលបន្ទាន់ធ្វើឲ្យចាំបាច់ត្រូវតែប្ដឹងដិតចិត្ត ពីព្រោះសាលដីកាលើសំណុំរឿង ០០២/០១ សម្រេចជាមុនលើបណ្ដឹងសាទុក្ខលើសំណុំរឿង ០០២/០១ ដែលជារឿងមិនអាចទទួលយកបាន (៣.២.២)។

### ៣.២.១ យុត្តិសាស្ត្រពាក់ព័ន្ធ

២៥. ***យុត្តិសាស្ត្ររបស់ អ.វ.ត.ក៖*** ពេលចាត់ការលើបណ្ដឹងដិតចិត្តចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលចាប់ផ្ដើមការជំនុំជម្រះក្ដីលើសំណុំរឿង ០០២/០២ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានយល់ឃើញថា លក្ខណៈវិនិច្ឆ័យដែលតុលាការកំពូលបានកំណត់ គឺចង់ដឹងថា តើការរកឃើញទាំងនេះ "អាចមានផលប៉ះពាល់លើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ទាក់ទងនឹងបទចោទ ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្ដីក្រោយៗទៀតដែរឬទេ"[38]។ បើតាមក្រុមប្រឹក្សាជំនុំជម្រះពិសេស "លក្ខណៈវិនិច្ឆ័យសំខាន់" គឺចង់ដឹងថា "តើសេចក្ដីសន្និដ្ឋាននៅក្នុងរឿងក្ដីមុន បង្កប់នូវការទម្លាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទចោទនានាដែលត្រូវវិនិច្ឆ័យ ក្នុងរឿងក្ដីក្រោយៗដែរឬទេ"[39]។ "សេចក្ដីលម្អៀងក្នុងការប្រកាន់យកជំហរជាក់លាក់ណាមួយ" មិនគ្រប់គ្រាន់ទេ[40]។

[37] សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម C11/29 កថាខណ្ឌ ២១ សូមមើលជើងទំព័រ ៨ ដែលស្រង់សម្ដីពីសាលដីកា *Furundzija* កថាខណ្ឌ ១៩០ ។ សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម E55/4 កថាខណ្ឌ ១២ ។ សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម E191/2 កថាខណ្ឌ ១៣។

[38] សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងដឹតចិត្ត E314/12/1 កថាខណ្ឌ ៥៤ ដែលស្រង់សម្ដីពី សេចក្ដីសម្រេចលើកទី៣ លើការបំបែកកិច្ចដំណើរការនីតិវិធី E301/9/1/1/3 កថាខណ្ឌ ៨៥។

[39] សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងដឹតចិត្ត E314/12/1 កថាខណ្ឌ ៧០។

[40] សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តចំពោះចៅក្រម E55/4 កថាខណ្ឌ ១៥ សូមមើលជើងទំព័រ ៣៦។ សំអាងហេតុចំពោះសេចក្ដី

២៦. នៅក្នុងមតិជំទាស់មួយផ្នែក ចៅក្រម Rowan DOWNING បានយល់ឃើញថា៖

"អង្គជំនុំជម្រះសាលាដំបូងបានទាញ**សេចក្ដីសន្និដ្ឋានលើបញ្ហាសំខាន់ៗមួយចំនួន** សម្រាប់ធ្វើការសម្រេចនៅក្នុងសំណុំរឿង 00២/0១ ដែល**អាចមានផលប៉ះពាល់លើការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល**របស់ នួន ជា និង **ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង 00២/0២**។ ខ្ញុំពិចារណាឃើញថា សេចក្ដីសន្និដ្ឋានទាំងនេះ គឺជា**សំអាងហេតុគ្រប់គ្រាន់** ដើម្បីសន្និដ្ឋានថា **អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ ដែលទទួលបានព័ត៌មានគ្រប់គ្រាន់អាចយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀងពីសំណាក់ចៅក្រមដែលត្រូវបានប្ដឹងជំទាស់**"[41]។

២៧. ពាក់ព័ន្ធនឹងសំណុំនៃតម្រុយដែលអាចឱ្យសម្រេចលើបញ្ហានេះបាន ចៅក្រម Rowan DOWNING បានបញ្ជាក់យ៉ាងមានប្រយោជន៍ថា៖

"**ផលប៉ះពាល់នៃការសម្រេចតាមផ្លូវតុលាការពីមុន** ទៅលើ**ការកំណត់ជាទូទៅអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ មានសារៈសំខាន់ខ្លាំង** នៅក្នុងក្របខ័ណ្ឌនៃការពិនិត្យលើការយល់ឃើញថាមានភាពលម្អៀងរហូតដល់ថ្នាក់**ការរកឃើញផ្នែកអង្គហេតុទាក់ទងនឹងការចូលរួមរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលកំពុងត្រូវជំនុំជម្រះ** អាចនាំឱ្យមានការប្ដឹងជំទាស់ ច្រើនជាងការរកឃើញពាក់ព័ន្ធនឹងបញ្ហាអង្គហេតុបន្ទាប់បន្សំ"[42]។

២៨. ទោះបីជាចៅក្រម Rowan DOWNING បានបញ្ចេញមតិបែបនេះក៏ដោយ ក៏បណ្ដឹងជំទាស់របស់មេធាវីការពារក្ដីត្រូវបានក្រុមប្រឹក្សាជំនុំជម្រះពិសេសបដិសេធចោល[43]។ ការបដិសេធបែបនេះមិនត្រឹមត្រូវទេ បើយោងលើយុត្តិសាស្ត្រថ្មីៗរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ដែលលើកស្ទួយសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់ក្ដីពីតុលាការអនាគតិ។

---

សម្រេចលើបណ្ដឹងជំទាស់ **E314/12/1** កថាខណ្ឌ ៦២។

[41] មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ១ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) ។

[42] មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ២៣ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[43] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ **E314/12**។

២៩. ***យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖*** កាលៈទេសៈខុសប្លែកពីគេនៃសំណុំរឿង ០០២/០២ ទាមទារឲ្យមានការប្រយ័ត្នប្រយែងកាន់តែខ្លាំងជាងនៅតុលាការអន្តរជាតិផ្សេងទៀត ដែលបានកាត់សេចក្តី ដោយគោរពយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍អនាគតិរបស់ចៅក្រម។ តុលាការកំពូលបានបញ្ជាក់ថា៖

> "យុត្តិសាស្ត្រ ដែលបានលើកឡើងនៅទីនេះរបស់តុលាការអន្តរជាតិចំពោះកិច្ច មិនពាក់ព័ន្ធនឹងរឿងក្តីដែលមានការបំបែកការពិនិត្យភ័ស្តុតាង ប៉ុន្តែនៅរក្សាលក្ខណៈរួមដដែល និងមិនពាក់ព័ន្ធនឹងរឿងក្តីដែលមានជនជាប់ចោទដដែល"[44]។

៣០. ករណីស្រដៀងគ្នាបំផុតនឹងស្ថានភាពបច្ចុប្បន្ននេះ គឺករណីរបស់ Ratko MLADIC ដែលបានចោទថាមានភាពលម្អៀងពីសំណាក់ចៅក្រម ដែលត្រូវបានចាត់តាំងឲ្យសម្រេចលើបណ្តឹងឧទ្ធរណ៍របស់គាត់ ដោយសារតែចៅក្រមទាំងនោះធ្លាប់បានទាញសេចក្តីសន្និដ្ឋានពីមុន នៅក្នុងការកាត់ទោសជនជាប់ចោទផ្សេងទៀត ដែលបានសម្រេចជាមុនលើពិរុទ្ធភាពរបស់គាត់ផ្ទាល់។ យន្តការអន្តរជាតិដែលត្រូវបានចាត់តាំងឲ្យបំពេញមុខងារនៅសេសសល់របស់តុលាការឧក្រិដ្ឋកម្ម បានឯកភាពតាមសំណើសុំប្តឹងជំទាស់ចៅក្រមទាំងនោះ។ សំណើទាំងនេះបានផ្អែកលើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងរូបគាត់របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក្រោមអធិបតីភាពចៅក្រម Theodor MERON ក្នុងរឿងក្តី *Krstic* និង *Tolimir* របស់អង្គជំនុំជម្រះសាលាដំបូង ក្រោមអធិបតីភាពចៅក្រម Carmel AGIUS ក្នុងរឿងក្តី *Popovic* និងរបស់អង្គជំនុំជម្រះសាលាដំបូង ក្រោមអធិបតីភាពចៅក្រម Daqun LIU ក្នុងរឿងក្តី *Blagojevic* និង *Jokic*។ អត្ថិភាពនៃការបារម្ភដោយសមហេតុផលពីភាពលម្អៀងត្រូវបានទទួលស្គាល់ និងដោះស្រាយ[45]។

---

[44] សេចក្តីសម្រេចលើកទី៣លើការបំបែកកិច្ចដំណើរការនីតិវិធី **E301/9/1/1/3** កថាខណ្ឌ ៨៣។ សូមមើលផងដែរ មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ៣ ៖ "ដោយសារមានការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ កាលៈទេសៈនៃរឿងក្តីបច្ចុប្បន្នមានលក្ខណៈពិសេស"។

[45] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Mladic* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីប្តឹងជំទាស់ចៅក្រម Theodor MERON, Carmel AGIUS និង Liu DAQUN, MICT-13-56-A ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម (*Mladic*)")។

៣១. សេចក្តីសម្រេចរបស់យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ លើសំណើសុំប្តឹងជំទាស់ចៅក្រម Theodor MERON ជាការស្រាយបំភ្លឺ ដោយសារវាពាក់ព័ន្ធនឹង "បរិបទពិសេសនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ"[46]។ សេចក្តីសម្រេចនោះបញ្ជាក់ថា៖

"ថ្វីត្បិតតែអង្គជំនុំជម្រះសាលាឧទ្ធរណ៍មានតួនាទីខុសពីអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចធ្វើអន្តរាគមន៍ ចំពោះសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ប្រសិនបើគ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានដូចគ្នា ឬកាលបើសេចក្តីសន្និដ្ឋាននេះខុសទាំងស្រុងតែម្តង។ ក្នុងការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពុំចាំបាច់ត្រូវតែយោង ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងរហូតនោះទេ គឺពេលខ្លះ អាចធ្វើសេចក្តីសន្និដ្ឋានជំនួស បដិសេធ ឬតម្កល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងអាចប្រើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបាន។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដើរតួនាទីជាតុលាការកំពូលផង និងជាសាលាជម្រះក្តីថ្នាក់ទីពីរផង"[47]។

"ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ ទោះបីជាលក្ខណៈវិនិច្ឆ័យនៃការពិនិត្យមានភាពខុសគ្នាក៏ដោយ ក៏ចៅក្រមត្រូវយល់ដឹងស៊ីជម្រៅលើសំណុំរឿង។ ហេតុនេះ ចៅក្រមក៏អាចវិភាគធាតុផ្សំដាក់បន្ទុក និងទាញសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់បុគ្គលម្នាក់ផ្សេងទៀត ដែលខ្លួនបានជំនុំជម្រះ នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងផ្សេងទៀត"[48]។

៣២. ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចមានលក្ខណៈគ្រប់គ្រាន់យកមកធ្វើជាមូលដ្ឋាននៃការចោទប្រកាន់អំពីអាការៈនៃភាពលម្អៀងបាន៖

"បើសិនពាក្យពេចន៍ខ្លះរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ធ្វើឲ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ និងទទួលបានព័ត៌មានគ្រប់គ្រាន់ គិតថា ចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍មានបុរេ

---

[46] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៤១។

[47] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៣៧ សូមមើលជើងទំព័រ ៤៨។

[48] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៤២។

វិនិច្ឆ័យមិនអាចទទួលយកបាន ទាក់ទិននឹងពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ នៅក្នុងរឿងក្ដីពាក់ព័ន្ធ”[49]។

៣៣. នៅក្នុងសេចក្ដីសម្រេចនេះរបស់យន្ដការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្ដរជាតិ ចៅក្រមទោល Jean-Claude ANTONETTI បានបញ្ជាក់ថា៖ “ការយោងដែលនាំទៅដល់ការទម្លាក់ការទទួលខុសត្រូវព្រហ្មទណ្ឌលើជនជាប់ចោទ Ratko MLADIC ពីបទឧក្រិដ្ឋដែលត្រូវបានប្ដឹងឧទ្ធរណ៍” ឬ “សេចក្ដីសន្និដ្ឋានរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើចេតនាប្រល័យពូជសាសន៍របស់សមាជិកអគ្គសេនាធិការកងទ័ពសាធារណរដ្ឋបូស្នី-អ៊ែរហ្សេហ្គោវីន” ដោយគ្មានកំណត់សម្គាល់ជើងទំព័រ ឬការយោងផ្ទាល់លើអង្គជំនុំជម្រះសាលាដំបូង អាចឲ្យច្រានចោលសច្ចធារណ៍អនាគត[50]។

៣៤. លើសពីនេះទៀត ចៅក្រម Jean-Claude ANTONETTI បានពិចារណាឃើញថា ទោះបីជា “ការយោងដាក់បន្ទុកធ្ងន់ធ្ងរបំផុតលើជនជាប់ចោទ មិនមែនជាសេចក្ដីសន្និដ្ឋានផ្ទាល់របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏ដោយ ក៏ការប្រមូលផ្ដុំសេចក្ដីយោងទាំងនេះ ក្នុងក្របខ័ណ្ឌនៃសាលដីកាពីរដាច់ដោយឡែកពីគ្នា ចោទជាបញ្ហា”[51]។ ចៅក្រមរូបនេះបានសន្និដ្ឋានអំពីអត្ថិភាពនៃ “ការយល់ឃើញថាមានបុរេវិនិច្ឆ័យ” ចំពោះ Ratko MLADIC ដោយសារតែ “សាលដីកា *Krstic* បានសំអាងថាជនជាប់ចោទ Ratko MLADIC ស្ថិតក្នុងចំណោមអ្នកបញ្ជា និងចូលរួមយ៉ាងសកម្មក្នុងការសម្លាប់” និង “ការយោងជាច្រើនផ្សេងទៀតដល់ជនជាប់ចោទ ក្នុងក្របខ័ណ្ឌនៃសាលដីកា *Krstic* និង *Tolimir*”[52]។ ចៅក្រម Jean-Claude ANTONETTI ក៏បានកត់សម្គាល់ផងដែរថា៖

“ចៅក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ រួមទាំងចៅក្រម Theodor MERON ផងដែរ បានប្រឈមមុខយ៉ាងខ្លាំងនឹងភស្ដុតាងក្នុងសំណុំរឿង និងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងចេតនាប្រល័យពូជសាសន៍ សមាជិកភាពក្នុងសហឧក្រិដ្ឋកម្មរួម និងតួនាទីស្នូលរបស់ឧត្ដមសេនីយ៍ Ratko MLADIC ក្នុងការរៀបចំផែនការ និងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលគាត់ជំទាស់តវ៉ានៅក្នុងប

[49] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម (*Mladic*) កថាខណ្ឌ ៣៨។

[50] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម (*Mladic*) កថាខណ្ឌ ៤៣-៤៦។

[51] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម (*Mladic*) កថាខណ្ឌ ៤៩។

[52] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម (*Mladic*) កថាខណ្ឌ ៤៩។

ណ្តឹងឧទ្ធរណ៍។ មានការយោងដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ជាបុគ្គល និងការទទួលខុសត្រូវរបស់គាត់ក្នុងឋានៈជាថ្នាក់លើ ជាច្រើនដង។ ដូច្នេះ យើង**លំបាកនឹងស្រមៃថា តើចៅក្រម Theodor MERON អាចចាត់ការលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ Ratko MLADIC បានយ៉ាងដូចម្តេច ដោយមិនទទួលរងឥទ្ធិពលពីភ័ស្តុតាងដាក់បន្ទុកដែលគាត់បានវិភាគប្រឆាំងនឹងជនជាប់ចោទ និងពីសេចក្តីសន្និដ្ឋានមុនៗរបស់គាត់ផ្ទាល់**"[53]។

"ការវិភាគលើការយោងដាក់បន្ទុកទាំងអស់លើ Ratko MLADIC បង្ហាញឲ្យឃើញថា ការបារម្ភអំពីភាពលម្អៀងពិតជាសមហេតុផល"[54]។

៣៥. ជាចុងក្រោយ សេចក្តីសម្រេចនេះរបស់យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ទទួលស្គាល់ដោយចំហនូវគ្រោះថ្នាក់នៃការចូលរួមរបស់ចៅក្រមក្នុងការជំនុំជម្រះក្តីច្រើនពាក់ព័ន្ធគ្នា និងបង្ហាញអំពីការបញ្ចប់ការអនុវត្តប្រថុយប្រថានទាក់ទិននឹងភាពអនាគតិ៖

"ក្នុងករណីអនុញ្ញាតឲ្យចៅក្រមខ្លះចូលរួមក្នុងការជំនុំជម្រះក្តីពីរដាច់ដោយឡែកពីគ្នា ដែលមានសំណុំអង្គហេតុដូចគ្នា កាលបើអង្គហេតុ ឬអង្គច្បាប់ រវាងរឿងក្តីទាំងនោះ មានលក្ខណៈរួមគ្នា តុលាការឧក្រិដ្ឋកម្មអន្តរជាតិបាន**ប្រឈមមុខ**នឹងភាពលម្អៀង"[55]។

៣៦. បន្ទាប់ពីមានយុត្តិសាស្ត្រនេះមក ចៅក្រម Theodor MERON បានស្ម័គ្រចិត្តដកខ្លួនចេញពីរឿងក្តី *Karadzic* ជាកិច្ចឆ្លើយតបទៅនឹងសំណើសុំប្តឹងជំទាស់ចៅក្រមគាត់ ដោយសារអាការៈនៃភាពលម្អៀង

---

[53] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៤៩។

[54] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៥២។

[55] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៨២។ សូមមើលផងដែរ កថាខណ្ឌ ៨៣៖ "ស្ថានភាពនោះ កាលពីអតីតកាល លំបាកក្នុងការចៀសផុត ដោយសារតុលាការព្រហ្មទណ្ឌអន្តរជាតិទទួលរឿងក្តីដែលនៅផ្តុំគ្នា ហើយចំនួនចៅក្រមមានកំណត់។ ក៏ប៉ុន្តែ ក្រៅពីការដែលថាការអនុវត្តបែបនោះត្រូវបានថ្កោលទោសដោយ តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុបនៅថ្នាក់ជាតិ យើងសូមវាយតម្លៃថាស្ថានភាពនោះមិនមានហេតុផលជាបង្អែកទៀតឡើយ នៅក្នុងក្របខណ្ឌបច្ចុប្បន្ននៃយន្តការ"។

ពីព្រោះចៅក្រមរូបនេះបានចូលរួមក្នុងការជំនុំជម្រះមុនៗលើជនជាប់ចោទផ្សេងទៀត ប៉ុន្តែ មានការទាញសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងជនជាប់ចោទ Radovan KARADZIC[56]។

៣៧. ***យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប៖*** ក្នុងរឿងក្តី Poppe ទល់នឹងប្រទេសហូល្លង់ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការដែលសាលក្រមមុនៗរបស់ចៅក្រមណាមួយបានទាញសេចក្តីសន្និដ្ឋានដែលមានបុរេវិនិច្ឆ័យជាក់ស្តែងលើបញ្ហាពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ ដែលនឹងត្រូវចោទប្រកាន់នៅពេលក្រោយ គឺគ្រប់គ្រាន់ឱ្យមានមន្ទិលសង្ស័យលើភាពអនាគតិរបស់ចៅក្រមនោះ[57]។ ជួនកាល សាលដីកានេះត្រូវបានបកស្រាយថា "ជាការតម្រូវឱ្យចៅក្រមរងបណ្តឹងជំទាស់ចិត្តសម្រេចលើគ្រប់ធាតុផ្សំទាំងអស់នៃបទល្មើសព្រហ្មទណ្ឌមួយ ដើម្បីឈានទៅដល់ការប្តឹងជំទាស់ចិត្តគាត់"[58]។ ប៉ុន្តែ ចៅក្រម Jean-Claude ANTONETTI និងចៅក្រម Rowan DOWNING បានអះអាងយ៉ាងត្រឹមត្រូវថា ការយោងនៅក្នុងរឿងក្តីនេះទៅលើធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌមួយ[59] "ជាការស្រាយបំភ្លឺ គឺមិនមែនជាលក្ខណៈវិនិច្ឆ័យដាច់ខាត សម្រាប់បង្ហាញអត្ថិភាពនៃការលម្អៀងនោះទេ"[60]។ ជាអាទិ៍ ចៅក្រមទាំងពីររូបនេះបានលើកឡើងថា ក្នុងរឿងក្តីផ្សេងទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសន្និដ្ឋានថា មានការរំលោភលើសិទ្ធិទទួលបានការកាត់ក្តីពីតុលាការអនាគតិ ខណៈដែលចៅក្រមរងបណ្តឹងជំទាស់ចិត្តមិនបានសម្រេចពីមុនលើធាតុផ្សំទាំងអស់នៃបទល្មើសទេ[61]។

---

[56] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Karadzic,* MICT-13-55-A *សេចក្តីសម្រេច* ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨។

[57] រឿងក្តី *Poppe តទល់នឹងប្រទេសហូឡង់* (បណ្តឹងលេខ n°32271/04) សាលដីកា ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៩ ("សាលដីកា *Poppe តទល់នឹងប្រទេសហូឡង់")* កថាខណ្ឌ ២៦។

[58] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ២៥។

[59] សាលដីកា *Poppe តទល់នឹងប្រទេសហូឡង់* កថាខណ្ឌ ២៨ ស្រង់សម្តីពីក្នុង មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ១៥។

[60] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ២៥ ស្រង់សម្តីពីជើងទំព័រ ៥៤ មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ១៦។

[61] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ២៥ និង ជើងទំព័រ ៥៥។ មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING **E314/12/1** កថាខណ្ឌ ១៦។

៣៨. ម្យ៉ាងវិញទៀត ក្នុងរឿងក្តី *Mancel* និង *Branquart* ទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបង្ហាញឲ្យឃើញអត្ថិភាពនៃការរំលោភលើសិទ្ធិទទួលបានការកាត់ក្តីពីតុលាការអនាគតិ ដោយហេតុថា៖

> "ការបារម្ភអំពីកង្វះអនាគតិកើតឡើង **ដោយសារតែចៅក្រម ៧ រូប ក្នុងចំណោមចៅក្រម ៩ រូប** នៃសភាព្រហ្មទណ្ឌ [នៃតុលាការកំពូល] ដែលបានសម្រេច នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ លើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទប្រឆាំងនឹងសាលដីកាផ្តន្ទាទោស **ធ្លាប់បានបំពេញមុខនាទី នៅអង្គជំនុំជម្រះដែលបានសម្រេច** នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០២ លើបណ្តឹងសាទុក្ខរបស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ទីក្រុងអាម្យៀង ប្រឆាំងនឹងសាលដីកាដោះលែង"[62]។

៣៩. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានកំណត់លក្ខណៈវិនិច្ឆ័យជាមូលដ្ឋាន សម្រាប់ដោះស្រាយករណីនេះ ពីព្រោះតុលាការកំពូលបំពេញតួនាទីជាសាលាជម្រះក្តីថ្នាក់លើបង្អស់ផង និងជាអង្គជំនុំជម្រះថ្នាក់ទីពីរផង[63]។ ចៅក្រមត្រូវរកឲ្យឃើញថា "តើបញ្ហា ដែលខ្លួនត្រូវដោះស្រាយក្នុងបណ្តឹងសាទុក្ខទីពីរ មានលក្ខណៈស្រដៀងគ្នានឹងបញ្ហាដែលខ្លួនបានដោះស្រាយក្នុងបណ្តឹងសាទុក្ខទីមួយដែរឬទេ"[64]។

៤០. ដូច្នេះ ស្ថានភាពរបស់ចៅក្រមរងបណ្តឹងជំទាស់ដែលជាចៅក្រមនៃតុលាការកំពូល ដែលត្រូវពិនិត្យ ដោយផ្អែកលើយុត្តិសាស្ត្ររឹងមាំរបស់យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអឺរ៉ុប បង្ហាញឲ្យឃើញភាពលម្អៀង ដោយគ្មានការសង្ស័យ។

## ៣.២.២. <u>បណ្តឹងជំទាស់ដែល ត្រូវតែធ្វើចាំបាច់ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធី និងដើម្បីទទួលបាននូវសិទ្ធទទួលបានការជំនុំជម្រះសេចក្តីដោយតុលាការពីរថ្នាក់</u>

[62] រឿងក្តី *Mancel និង Branquart ទល់នឹងប្រទេសបារាំង* (បណ្តឹងលេខ n°022349/06) សាលដីកា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៣៦ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) ។

[63] មាត្រា ៣៦ នៃច្បាប់បង្កើត អ.វ.ត.ក ។ វិធាន ១០៤ នៃវិធានផ្ទៃក្នុង។ សូមមើល សេចក្តីពិចារណារបស់ MICT *ខាងលើ* កថាខណ្ឌ ៣១។

[64] រឿងក្តី *Mancel និង Branquart ទល់នឹងប្រទេសបារាំង* (បណ្តឹងលេខ n°022349/06) សាលដីកា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៣៧។

៤១. សំណើសុំនេះគឺជាផលវិបាកដោយផ្ទាល់នៃការបំបែកដ៏ចម្រូងចម្រាសនូវសំណុំរឿង០០២ ជាពីរវគ្គ ដែលមានធាតុផ្សំអង្គហេតុនិងអង្គច្បាប់ពាក់ព័ន្ធត្រួតគ្នា ហើយលែងធានាបាននូវភាពមិនលំអៀង (ក)។ ការពិនិត្យពិចារណាលើសំណុំរឿង ០០២/០២ ដោយចៅក្រមតុលាការកំពូលទាំងប្រាំមួយរូបដែលរងប្តឹងឧទ្ធរណ៍ បង្កព្យសនកម្មដល់សិទ្ធិទទួលបាននូវការជំនុំជម្រះដោយតុលាការពីថ្នាក់ខុសគ្នា (ខ)។ ជាក់ស្តែង សេចក្តីសន្និដ្ឋាននៃសាលដីកា ក្នុងសំណុំរឿង ០០២/០១ បានកំណត់ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ក្នុងបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿង ០០២/០២ (គ)។

## ៣.២.២.១, ការប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រឹត បណ្តាលមកពីភាពត្រួតគ្នានៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២

៤២. សំណុំរឿង ០០២ ត្រូវបានបំបែក តាមរបៀបថ្មីមិនធ្លាប់មាន និងចម្រូងចម្រាស ដែលបណ្តាលឲ្យមានការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមិនលំអៀង។

៤៣. **ខៀវ សំផន** ត្រូវបានចោទប្រកាន់ដោយដីកាដំណោះស្រាយ ក្រោមហេតុផលថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានផែនការរួម សំដៅ "សម្រេចឱ្យបាននូវបដិវត្តសង្គមនិយមឆាប់រហ័សនៅកម្ពុជា តាមគ្រប់មធ្យោបាយចាំបាច់ តាមជំហានមហាអស្ចារ្យ មហាលោតផ្លោះ និងដោយការពារបក្សប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ"[65]។ ផែនការនេះទំនងជាត្រូវបានអនុវត្តតាមរយៈគោលនយោបាយចំនួនប្រាំ[66]។

---

[65] ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ១៥២៤។

[66] ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ១៥២៥។ គោលនយោបាយទាំងប្រាំមានដូចជា ៖ (១). ការផ្លាស់ទីលំនៅប្រជាជនជាច្រើនដង ពីទីប្រជុំជនទៅជនបទ និងពីជនបទមួយទៅជនបទមួយទៀត (២). ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋាននានា (៣). ការអប់រំកែប្រែ "សមាសភាពមិនល្អ"និង ការកម្ទេច "ខ្មាំង ទាំងនៅក្នុង និងនៅក្រៅបក្ស (៤). ការចេញនូវវិធានការចំពោះក្រុមមនុស្សជាក់លាក់ ជាពិសេសជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលមានជាអាទិ៍ មន្ត្រី ទាហាន និង គ្រួសាររបស់ពួកគេ) និង (៥). ការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍។

៤៤. ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ គឺជាករណីពិសេសដោយឡែកមួយ។ មិនដែលមានយុត្តិសាស្ត្រណាមួយកន្លងមក ដែលដីកាចោទប្រកាន់លើជនជាប់ចោទត្រូវបានបំបែកទៅជាការជំនុំជម្រះសេចក្តីជាច្រើនវគ្គបន្តបន្ទាប់គ្នា ហើយដែលវគ្គទាំងនេះចេញមកពីសំណុំរឿងតែមួយ និងអនុវត្តចំពោះជនជាប់ចោទដដែល។ កន្លងមក ការបំបែកសំណុំរឿងមួយត្រូវបានបង្គាប់ឱ្យអនុវត្ត តែក្នុងករណីដែល "ការបំបែកសំណុំរឿងនោះមានគោលបំណងតែមួយគត់ គឺបំបែកការជំនុំជម្រះសេចក្តីលើបុគ្គលមួយចំនួនដាច់ដោយឡែកចេញពីគេ ក្នុងករណីដីកាចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទច្រើននាក់"[67]។

៤៥. ដូចតុលាការកំពូលបានទទួលស្គាល់ក្នុងសេចក្តីសម្រេចលើកទីមួយរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធី៖

> "ភាពចាំបាច់នៃប្រសិទ្ធភាពនិងយុត្តិធម៌ត្រូវតែគាំទ្រពង្រឹង**គោលការណ៍ទូទៅដែលជាបង្អែកនៃច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក និងនៅតុលាការអន្តរជាតិនានា** ហើយដែលគោលការណ៍នេះចែងថា ចៅក្រមគួរគប្បីពិនិត្យពិចារណាក្នុងក្របខណ្ឌនៃនីតិវិធីរួមតែមួយ ចំពោះការចោទប្រកាន់មួយចំនួនប្រឆាំងនឹងជនជាប់ចោទច្រើននាក់ ពាក់ព័ន្ធនឹងអង្គហេតុស្រដៀងគ្នា។ **ការបំបែកអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានតម្កល់ មិនមានចែងដោយច្បាប់កម្ពុជា និងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះកិច្ច ហើយទន្ទឹមនឹងនោះ តុលាការអន្តរជាតិចំពោះកិច្ច ក៏ធ្លាប់បង្ហាញថាខ្លួនមិនស្វាគមសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីដែរ។** ជាទូទៅ ក្នុងករណីយល់ឃើញថាចាំបាច់ វិធានការបែបនេះត្រូវបំបែកការចោទប្រកាន់លើលើជនជាប់ចោទណាម្នាក់។ ដូច្នេះសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីធ្វើឡើងតែក្នុងករណីលើកលែង ផ្ទុយពីការជំនុំជម្រះរួមដែលជាការអនុវត្តទូទៅ"[68]។

៤៦. ចៅក្រមត្រូវតែចងចាំអំពីលក្ខណៈពិសេសមិនធ្លាប់មាន នៃការបំបែកកិច្ចដំណើរការនីតិវិធីដែលត្រូវបានធ្វើឡើងទាំងពពឹងពពើម ដែលស្តែងចេញជាគ្រោះថ្នាក់បន្តបន្ទាប់ដល់សិទ្ធិទទួលបានការជំនុំ

---

[67] សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី - សំអាងហេតុ **284/4/8** កថាខណ្ឌ ៤០។

[68] សេចក្តីសម្រេចលើកទីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/1/3** កថាខណ្ឌ ៣៣ (យើងជាអ្នកដាក់អក្សរដិត)។ សូមមើលផងដែរ ៖ សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី - សំអាងហេតុ **284/4/8** កថាខណ្ឌ ៣៩, ៤០ និង សេចក្តីសម្រេចលើកទីបីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E301/9/1/1/3** កថាខណ្ឌ ៥១។

ជម្រះដោយយុត្តិធម៌។ ការបំបែកកិច្ចដំណើរការនីតិវិធីតែមួយគត់នេះ ទាំងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទាំងក្នុងច្បាប់ជាតិ ត្រូវបានធ្វើឡើងក្នុងសភាពវឹកវរ។ វិវាទដ៏ធ្ងន់ធ្ងរដែលរួតរឹតសំណុំរឿង ០០២០/១ និង ០០២/០២ បង្ហាញពីការរំលោភសច្ចធម៌គតិយុត្ត ដែលកើតចេញពីសារជាតិ និងទ្រង់ទ្រាយមិនច្បាស់លាស់នៃការបំបែកកិច្ចដំណើរការនីតិវិធី[69]។

៤៧. ក្នុងពេលជំនុំជម្រះសេចក្តីលើសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល និងនៅក្នុងសំណុំរឿង ០០២/០២ នៅចំពោះមុខសាលាដំបូង បញ្ហាជាច្រើនត្រូវបានចោទឡើង ពាក់ព័ន្ធនឹងអព្យាក្រឹតភាពរបស់ចៅក្រម នៅក្នុងក្របខណ្ឌនៃការបំបែកកិច្ចដំណើរការនីតិវិធី។ ជាក់ស្តែង នេះគឺជាករណីនៃការរកឃើញអង្គហេតុដែលមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តី ០០២/០១ និង/ឬ ការកាត់សេចក្តីលើការជំនុំជម្រះលើសំណុំរឿង ០០២/០២[70]។

៤៨. តាំងពីនៅដំណាក់កាលជំនុំជម្រះចំពោះមុខអង្គជំនុំជម្រះសាលាដំបូង **តុលាការកំពូលខ្លួនឯងផ្ទាល់** បានផ្តល់អនុសាសន៍យ៉ាងច្បាស់លាស់ឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដើម្បី **"ដោះស្រាយបញ្ហាលំអៀងជាក់ស្តែងឬច្បាស់ក្រឡែត ដែលអាចត្រូវបានលើកឡើងប្រឆាំងនឹងចៅក្រមនៃការជំនុំជម្រះក្តីវគ្គមួយដែលត្រូវបានអញ្ជើញមកកាត់សេចក្តីវគ្គពីរទៀត"**[71]។

---

[69] ក្រៅពីបណ្តឹងជំទាស់ចិត្តលើសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ដូចបង្ហាញខាងលើ (កថាខណ្ឌ ២) និងកិច្ចពិភាក្សាដេញដោលជាច្រើននៅក្នុងសវនាការ សូមមើល ៖ ការបញ្ជាក់បំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពី សំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ E302/5 ។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូលដលមានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៤ ឯកសារ E301/5/5/1 ។ សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ E307/1។

[70] ជាឧទាហរណ៍ សូមមើល ៖ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ឯកសារ E457/6/4 កថាខណ្ឌ ៦៥១-៦៥៨។

[71] សេចក្តីសម្រេចលើកទីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E163/5/1/1/3 កថាខណ្ឌ ៥១ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

៤៩. នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ តុលាការកំពូលបានលើកឡើងអំពីបញ្ហានៃភាពមិនលំអៀង និងបានគូសបញ្ជាក់អំពីការមិនយកចិត្តទុកដាក់របស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ៖

"ប្រសិទ្ធិភាពមិនដាច់ខាតនៃការជំនុំជម្រះជាវគ្គខ្លីៗច្រើន ធៀបទៅនឹងការជំនុំជម្រះរឿងក្តីធំរួមតែមួយគួរ តែត្រូវបានវាយតម្លៃ [...] (vi) ដោយថ្លឹងថ្លែងអំពីបញ្ហាច្បាប់ និងបញ្ហាចាត់ចែងការជំនុំជម្រះ ក្នុងករណី ដែលចៅក្រមជំនុំជម្រះវគ្គមួយត្រូវបានតែងតាំងឲ្យមកកាត់សេចក្តីវគ្គពីរទៀត ដោយហេតុថាគប្បីប្រមើលទុកជាមុននូវរឿងដែល**ភាគីណាមួយអាចលើកឡើងអំពីបញ្ហាលំអៀង ឬក៏អាការៈលំអៀងរបស់អង្គជំនុំជម្រះ** និងផលប៉ះពាល់ដែលកើតចេញពីការតាក់តែងសាលក្រមនៃការជំនុំជម្រះវគ្គមួយទៅលើដំណើការនីតិវិធីយ៉ាងលឿនរហ័សនៃវគ្គជំនុំជម្រះទីពីរ[72]"។

"អង្គជំនុំជម្រះសាលា**ដំបូងខកខានមិនបានលើកយកបញ្ហានៃការរំលោភបំពានជាសក្តានុពល ទៅលើសិទ្ធិជនជាប់ចោទ ដោយសារមានភាពលំអៀងឬអាការៈនៃភាពលំអៀង**របស់ក្រុមចៅក្រមដែលជំនុំជម្រះសេចក្តីវគ្គជាបន្ត បន្ទាប់ក្រោយទៀត ប្រសិនបើនៅទីបញ្ចប់នៃ [ការជំនុំជម្រះក្តី ០០២/០១ ] នឹងមានការផ្តន្ទាទោស"[73]។

៥០. អាស្រ័យដូច្នេះហើយបានជាតុលាការកំពូលនៅតែចេញសេចក្តីសម្រេចគាំទ្រភាពចាំបាច់នៃការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ[74]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានបដិសេធសេចក្តីសម្រេចនេះ[75]។ ហេតុដូច្នេះហើយបានជានៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីបីរបស់ខ្លួន

---

[72] សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី - សម្អាងហេតុ **284/4/8** កថាខណ្ឌ ៣៩ (យើងជាអ្នកដាក់អក្សរដិត)។

[73] សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី - សម្អាងហេតុ **284/4/8** កថាខណ្ឌ ៤៦ (យើងជាអ្នកដាក់អក្សរដិត)។

[74] សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី - សម្អាងហេតុ **284/4/8** កថាខណ្ឌ ៧៣-៧៤។ ដីកាទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E284/4/7/1**។ សេចក្តីសម្រេចលើកទីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/1/3** កថាខណ្ឌ ៥១។

[75] អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ **E301/4** កថាខណ្ឌ ១០។

តុលាការកំពូលនៅតែសង្កត់ធ្ងន់លើបញ្ហានៃភាពមិនលំអៀងដែលមិនទាន់បានដោះស្រាយ និងបង្កផលលំបាកជាបន្តបន្ទាប់ទៅទៀត៖

> "ក្នុងការកាត់សេចក្តីជាវគ្គតូចៗដាច់ដោយឡែកជាបន្តបន្ទាប់ ប្រសិនបើចៅក្រមដដែលជាអ្នកជំនុំជម្រះលើការចោទប្រកាន់ជាច្រើនប្រឆាំងនឹងជនជាប់ចោទម្នាក់ដដែល **វានឹងមានបញ្ហាពាក់ព័ន្ធនឹងភាពមិនលំអៀងរបស់ពួកគាត់ នៅត្រង់ហេតុថាពួកគាត់ត្រូវតែសម្រេចលើផ្នែកណាមួយនៃការចោទប្រកាន់ទាំងឡាយដែលជាកម្មវត្ថុនៃរឿងក្តីកំពុងជំនុំជម្រះ ក្នុងខណៈដែលនៅវគ្គជំនុំជម្រះមុន ពួកគាត់បានធ្វើការសន្និដ្ឋានទុកជាមុនលើអង្គហេតុទាក់ទងនឹងការចោទប្រកាន់ទាំងនោះរួចបាត់ទៅហើយ។ វត្តមានចៅក្រមដដែលអាចបង្កការព្រួយបារម្ភថាមានភាពលំអៀង (ឬអាការៈនៃភាពលំអៀង) ប្រឆាំងនឹងជនជាប់ចោទ។** ដូចដែលយើងបានបញ្ជាក់រួចមកហើយ ការព្រួយបារម្ភនេះត្រូវតែលើកយកមកពិចារណានៅក្នុងយុត្តិសាស្ត្រអន្តរជាតិ និងប្រព័ន្ធច្បាប់ក្នុងស្រុក"[76]។
>
> "ក្នុងករណីដែលនៅទីបញ្ចប់នៃការជំនុំជម្រះវគ្គទីមួយ សាលក្រមសម្រេចផ្តន្ទាទោស **វានឹងមានហានិភ័យ ត្រង់ថាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញដាក់បន្ទុកទំនួលខុសត្រូវព្រហ្មទណ្ឌលើជនជាប់ចោទទាំងអស់នៅក្នុងវគ្គជំនុំជម្រះនេះ ដូច្នេះ វានឹងនាំឱ្យអង្គជំនុំជម្រះរក្សាការវិនិច្ឆ័យរបស់ខ្លួនដដែល នៅពេលដែលខ្លួនពិចារណា សម្រេចលើបញ្ហាទំនួលខុសត្រូវជាបុគ្គលរបស់ជនជាប់ចោទ ក្នុងវគ្គជំនុំជម្រះក្រោយៗទៀត**"[77]។

៥១. ភាពជជេសរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដើម្បីជំនុំជម្រះទាំងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ បាននាំឱ្យក្រុមមេធាវីការពារក្តីដាក់បណ្តឹងជិតចិត្តចំពោះចៅក្រមទាំងនេះពីបទខ្វះភាពមិនលំអៀង[78]។ ដោយបដិសេធបណ្តឹងទាំងនេះ[79] ជាអកុសល ក្រុមប្រឹក្សាជំនុំ

---

[76] ឯកសារ E301/9/1/1/3 កថាខណ្ឌ ៩៥ ។(ដិតអក្សរដាក់អ្នកជាយើង)

[77] ឯកសារ E301/9/1/1/3 កថាខណ្ឌ ៨៥ ។(ដិតអក្សរដាក់អ្នកជាយើង)

[78] សំណើរបស់ លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២ចូលជា ០១/ និង ០២/០០២ស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង សុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E314/1 ។ បណ្តឹងជិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម JEAN-MARC Lavergne និងចៅក្រម យូរ ឧត្តរា ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E314/6 ។ បណ្តឹងជិតចិត្តសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២០២/ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ឯកសារ E314/8។

[79] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E314/12 និង

ជម្រះពិសេស ខកខានមិនបានអនុវត្តវិធីសាស្ត្រដែលធានានូវសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានការវិនិច្ឆ័យដោយសាលាក្តីមិនលំអៀង និងវិធីសាស្ត្រដែលធានាឲ្យបាននូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ ដោយឡែក នៅក្នុងមតិជំទាស់ដោយផ្នែករបស់គាត់ ចៅក្រម DOWNING ប្រកាសគាំទ្រយ៉ាងត្រឹមត្រូវដល់ការដកខ្លួនរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ដោយផ្តល់ទឡ្ហីករណ៍ដែលមេធាវីការពាក្តីនឹងរៀបរាប់នៅផ្នែកខាងក្រោម។ ដោយសង្កត់ធ្ងន់លើលក្ខណៈពិសេសនៃស្ថានភាពច្បាប់ដែលកើតចេញការបំបែកកិច្ចដំណើរការនីតិវិធីនេះ លោកបានលើកឡើងជាពិសេសថា៖

> "នេះជាលើកទីមួយហើយដែលនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ចៅក្រមត្រូវបានស្នើសុំឱ្យសម្រេចលើរឿងក្តីពីរដាច់ដោយឡែកពីគ្នា ដែលកើតចេញពីដីកាចោទប្រកាន់ដូចគ្នា ប្រឆាំងនឹងជនជាប់ចោទដូចគ្នា។ ទោះបីជា [សំណុំរឿង ០០២/០១ និង ០០២/០២] ទាក់ទងនឹងការចោទប្រកាន់ផ្សេងៗគ្នាក៏ដោយ **ក៏វាមានអង្គហេតុជាច្រើនដែលត្រួតស៊ីគ្នាដែរ**"[80]។

៥២. "ភាពត្រួតគ្នាដ៏សម្បើមនៃអង្គហេតុ" និងអង្គច្បាប់ ផ្តល់យុត្តិកម្មដល់បណ្តឹងជំទាស់ចិត្តនេះ ពីព្រោះចៅក្រមដែលរងបណ្តឹងជំទាស់ចិត្ត សុទ្ធតែបានទាញការសន្និដ្ឋានទុកជាមុនលើធាតុផ្សំនៃអង្គហេតុនិងអង្គច្បាប់មួយចំនួនរួចបាត់ទៅហើយ។

៥៣. ចៅក្រមប្រាំមួយរូបនៃតុលាការកំពូល បានចេញសេចក្តីសម្រេច និងផ្តន្ទាទោស ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹងជនជាប់ចោទតែមួយ និងចំពោះបញ្ហាស្រដៀងៗគ្នា។ ដូច្នេះ ចៅក្រមទាំងនោះស្ថិតក្នុងស្ថានភាពដូចគ្នានឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងខណៈដែលពួកគាត់ខ្លួនឯងផ្ទាល់បានណែនាំឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ។ បើនិយាយជាសម្រាយអំពីដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី ដូចគ្នាសម្រាប់ចៅក្រមជំនុំជម្រះសាលាដំបូងដែរ វានឹងមានហានិភ័យត្រង់ថា ការណ៍ដែលចៅក្រមតុលាការកំពូលទាំងប្រាំមួយរូបរកឃើញថាជនជាប់ចោទទាំងអស់ "មានទំនួលខុសត្រូវព្រហ្មទណ្ឌ នៅក្នុងវគ្គជំនុំជម្រះនេះ នឹងនាំឲ្យពួកគាត់រក្សាការវិនិច្ឆ័យរបស់ខ្លួនដដែល នៅពេលដែលខ្លួនពិចារណាសម្រេចលើបញ្ហាដដែលពាក់ព័ន្ធនឹងទំនួលខុសត្រូវ

---

សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត ឯកសារ **E314/12/1**។

[80] មតិជំទាស់មួយផ្នែករបស់ចៅក្រម Rowan DOWNING **E314/12/1** កថាខណ្ឌ ៣ (យើងជាអ្នកដាក់អក្សរដិត)។

ព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ”។ បញ្ហានេះនឹងកើតឡើងដូចគ្នា នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍៖

> “ក្នុងការកាត់សេចក្តីជាវគ្គខ្លីៗដាច់ដោយឡែកពីគ្នាជាបន្តបន្ទាប់ ប្រសិនបើចៅក្រមដែលជាអ្នកជំនុំជម្រះលើការចោទប្រកាន់ជាច្រើនប្រឆាំងនឹងជនជាប់ចោទម្នាក់ដដែល វាអាចមានបញ្ហាពាក់ព័ន្ធនឹងភាពមិនលំអៀងរបស់ពួកគាត់ នៅត្រង់ហេតុថាពួកគាត់នឹងត្រូវសម្រេចលើផ្នែកណាមួយនៃការចោទប្រកាន់ទាំងឡាយដែលជាកម្មវត្ថុនៃរឿងក្តីកំពុងជំនុំជម្រះ ក្នុងខណៈដែលកាលពីវគ្គជំនុំជម្រះមុន ពួកគាត់បានទាញការសន្និដ្ឋានទុកជាមុនលើអង្គហេតុទាក់ទងនឹងការចោទប្រកាន់ទាំងនោះរួចបាត់ទៅហើយ។ ប្រការនេះអាចបង្កការព្រួយបារម្ភថាពួកគាត់មានភាពលំអៀង (ឬអាការៈនៃភាពលំអៀង) ប្រឆាំងនឹងជនជាប់ចោទ”[81]។

៥៤. ជាការគោរពដោយមិនអាចខកខានបានចំពោះគោលការណ៍សិទ្ធិទទួលបានការជំនុំជម្រះដោយមិនលំអៀងនិងដោយអនុលោមតាមវិធាន ៣៤ (១) នៃវិធានផ្ទក្នុង ចៅក្រមចៅក្រមទាំងប្រាំមួយរូបគួរតែដកខ្លួនដោយស្ម័គ្រចិត្តចេញពីបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២ ដោយគោរពតាមសិទ្ធិអំណាច និងកាតព្វកិច្ចរបស់ខ្លួន ដោយមូលហេតុថាមានភាពលំអៀង ឬអាការៈលំអៀង[82]។ អនុលោមតាមគោលការណ៍ដែលពួកគាត់បានអនុម័តដោយខ្លួនឯងផ្ទាល់ នៅក្នុងសេក្តីសម្រេចដែលបានរៀបរាប់ខាងលើ វាមិនទាន់ហួសពេលនៅឡើយទេចំពោះពួកគាត់ ក្នុងការអនុវត្តតាមអនុសាសន៍ដែលខ្លួនឯងផ្ទាល់បានផ្តល់ទៅអង្គជំនុំជម្រះសាលាដំបូង (វិធាន ៣៤-៥ នៃវិធានផ្ទៃក្នុង) និងក្នុងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវស្របតាមកាតព្វកិច្ចនេះ។

៥៥. នៅដំណាក់កាលបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធី និងប្រឈមមុខនឹងបញ្ហានៃភាពមិនលំអៀងដែលចោទឡើងនៅក្នុងការកំណត់រចនាសម្ព័ន្ធថ្មីនៃសំណុំរឿងក្រោយការបំបែកកិច្ចដំណើរការនីតិវិធី ការដកខ្លួនរបស់ចៅក្រមតុលាការកំពូល ដោយស្ម័គ្រចិត្តក្តី ដោយមិនស្ម័គ្រចិត្តក្តី ជាវិធីតែមួយគត់ដើម្បីធានាឲ្យបាននូវការជំនុំជម្រះសេចក្តីដោយតុលាការពីរថ្នាក់ខុសគ្នា។

---

[81] សេចក្តីសម្រេចលើកទីបីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E301/9/1/1/3 កថាខណ្ឌ ៤៥។

[82] សេចក្តីសម្រេចលើកទីបីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E301/9/1/1/3 កថាខណ្ឌ ៤៥ សូមមើលជើងទំព័រ ៩៥ ដែលផ្តល់បញ្ជីឯកសារយោងលម្អិតនៃយុត្តិសាស្ត្រអន្តរជាតិ។

## ៣.២.២.២. ការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះសេចក្ដីដោយតុលាការពីរថ្នាក់

៥៦. នៅ **អ.វ.ត.ក** តុលាការកំពូល "ត្រូវតែសម្រេចជាចុងក្រោយលើបញ្ហាច្បាប់និងបញ្ហាអង្គហេតុ ដោយមិនចាំបាច់បញ្ជូនរឿងក្ដីទៅអង្គជំនុំជម្រះសាលាដំបូងវិញ"[83]។ តួនាទីរបស់ចៅក្រមនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍នេះមានសារៈសំខាន់ណាស់ ពីព្រោះវាជាតុលាការថ្នាក់ទីពីរ និងចុងក្រោយបង្អស់សម្រាប់ **ខៀវ សំផន** ដែលត្រូវបានផ្ដន្ទាទោសឲ្យជាប់ពន្ធនាគាររហូតដល់មួយជីវិត។

៥៧. ចៅក្រមក្នុងសំណុំរឿង ០០២/០១ ដែលបានសម្រេចលើបញ្ហាអង្គច្បាប់និងអង្គហេតុជាច្រើន ដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ប្រឡាក់ប្រឡូកទៅដោយភាពលំអៀង។ បើយោងតាមសម្ដីរបស់ចៅក្រម ANTONETTI[84] នៃផ្នែកយន្ដការតុលាការព្រហ្មទណ្ឌនៃអង្គការសហប្រជាជាតិ (MICT) គេមិនអាចស្រមៃបានថាតើចៅក្រមទាំងប្រាំមួយរូបនេះអាចពិចារណាអំពីសំណុំរឿង ០០២/០២ បានយ៉ាងដូចម្ដេច ដោយមិនទទួលឥទ្ធិពលពីធាតុផ្សំដាក់បន្ទុកលើ ខៀវ សំផន និងពីសេចក្ដីសន្និដ្ឋានដែលពួកគាត់បានទាញចេញដោយខ្លួនឯងកាលពីពេលមុននៅក្នុងសំណុំរឿង ០០២/០១។

៥៨. ចៅក្រមរងបណ្ដឹងជំទាស់មិនអាចទទួលយកបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ដោយមិនរំលោភសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្ដីដោយតុលាការមិនលំអៀង សិទ្ធិទទួលបានការកាត់សេចក្ដីដោយតុលាការពីរថ្នាក់ខុសគ្នា និងគោលការណ៍សច្ចធានិរទោស។ សាលដីកានៃសំណុំរឿង ០០២/០២ នឹងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង **ខៀវ សំផន**។ ដូច្នេះ ការធានាភាពមិនលំអៀងរបស់ចៅក្រមទាំងនេះក្នុងការស្ដាប់រឿងក្ដីរបស់លោក **ខៀវ សំផន** ហាក់កាន់តែមានសារៈសំខាន់ខ្លាំង។

---

[83] មាត្រា ៣.២-ខ នៃកិច្ចព្រមព្រៀង។ សូមមើលផងដែរ មាត្រា ៣៦ នៃច្បាប់បង្កើត អ.វ.ត.ក ។ វិធាន ១០៦ នៃវិធានផ្ទៃក្នុង។

[84] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចំពោះចៅក្រម (*Mladic*) កថាខណ្ឌ ៤៩ និង ៦៧។

៥៩. ភស្តុតាងជាសំអាងខាងក្រោមនៅក្នុងសាលដីកានៃសំណុំរឿ ០០២/០១ មិនមែនគ្រាន់តែជាទំនោរដែលចៀសមិនរួច ក្នុងការប្រកាន់គោលជំហរមួយចំនួន ចំពោះញ្ហាដែលបានចោទឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែគោលជំហរទាំងនេះបង្ហាញពីអត្ថិភាពនៃជំនឿស្ទើរតែទាំងស្រុងថា តុលាការកំពូលនឹងចេញសេចក្តីសម្រេចផ្តន្ទាទោស **ខៀវ សំផន**។ ជាក់ស្តែងរបៀបដែលចៅក្រមចេញសាលដីកានៃសំណុំរឿង ០០២/០១ មិនអនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍អនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២ បានទេ ប្រសិនបើពួកគាត់មិនបដិសេធមិនទទួលរឿងក្តីនេះយកមកជំនុំជម្រះ។

## ៣.២.២.៣. <u>សាលដីកានៃសំណុំរឿង ០០២/០១ ជាបុរេវិនិច្ឆ័យលើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន សម្រាប់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២</u>

៦០. មេធាវីការពារក្តីសូមយោងទៅឧបសម្ព័ន្ធដែលមានភាពក្បោះក្បាយតាមដែលអាចធ្វើបាន ដែលបង្ហាញយ៉ាងលម្អិត និងច្បាស់លាស់អំពីទំហំនៃភាពត្រួតស៊ីគ្នានៃកំហុសទាំងឡាយដែលបានលើកឡើង នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួន និងដែលស្តែងឡើងតាមរយៈការទាញសេចក្តីសន្និដ្ឋាននៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១[85]។ ឥឡូវនេះ មេធាវីការពារក្តីគ្រាន់តែលើកសេចក្តីសន្និដ្ឋានលើអង្គហេតុ (i) និងអង្គច្បាប់ (ii) មួយចំនួន ដែលត្រូវបានធ្វើឡើងដោយចៅក្រមរងបណ្តឹងជិតចិត្ត ដោយមូលហេតុពួកគាត់មានបុរេវិនិច្ឆ័យលើលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២។

### i. <u>ការទាញសេចក្តីសន្និដ្ឋានលើអង្គហេតុដែលកំណត់ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន</u>

៦១. ចៅក្រមរងបណ្តឹងជិតចិត្តបានទាញការសន្និដ្ឋានផ្នែកអង្គហេតុដែលពាក់ព័ន្ធនឹងស្នូលនៃទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០២។ សេចក្តីសន្និដ្ឋានទាំងនេះទាក់ទង

[85] ឧបសម្ព័ន្ធ ១ ដល់ ១៦ បង្ហាញជាទម្រង់តារាងនូវកំហុសឆ្គងដែលបានស្រង់ចេញពីសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ (រួមបញ្ចូលទាំងកថាខណ្ឌស្តីពីសម្អាងហេតុនៃសាលក្រម ០០២/០២) ជាមួយនឹងកថាខណ្ឌពាក់ព័ន្ធនឹងសាលដីកា ០០២/០១ ដែលលើកឡើងពីបុរេវិនិច្ឆ័យពាក់ព័ន្ធបញ្ហាទាំងនោះ។

នឹងគោលនយោបាយឧក្រិដ្ឋរងការចោទប្រកាន់ រួមមាន គោលនយោបាយបង្កើតសហករណ៍ និងការដ្ឋានការងារ និងការចាត់វិធានការប្រឆាំងនឹងក្រុមជាក់លាក់នៃអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (អតីតសាធារណរដ្ឋខ្មែរ) សំដៅកម្ទេចខ្មាំង និងទាក់ទងជាពិសេសទៅនឹងទំនួលខុសត្រូវព្រហ្មទណ្ឌក្រោមទម្រង់សហឧក្រិដ្ឋកម្ម[86]។

៦២. ***សហករណ៍ និងការដ្ឋានការងារ៖*** ចៅក្រមរងបណ្តឹងឧទ្ធរណ៍ទាំងប្រាំមួយរូបបានបញ្ជាក់ពីអត្ថិភាព និងគោលបំណងនៃគោលនយោបាយផ្លាស់ទីលំនៅរបស់ប្រជាជន នៅក្នុងការជំនុំជម្រះក្តីវគ្គ ០០២/០១។ តាមរយៈការបញ្ជាក់នេះ ពួកគាត់មានបុរេវិនិច្ឆ័យបាត់ទៅហើយលើអត្ថិភាពនៃគោលនយោបាយដើម្បីបង្កើតការដ្ឋានការងារ ដែលចំពោះពួកគាត់ បើគ្មានគោលនយោបាយនេះទេ វាគ្មានការដ្ឋាននោះទេ[87]។ ជាពិសេស ពួកគាត់បានវិនិច្ឆ័យ៖

> "ពិតណាស់ ឧក្រិដ្ឋកម្មដែលទំនងជាត្រូវបានប្រព្រឹត្តតាមសហករណ៍ និងតាមការដ្ឋាន មិនស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះក្តីលើកដំបូងនៃសំណុំរឿង ០០២ ទេ ប៉ុន្តែមិនមែនមានន័យថាអង្គជំនុំជម្រះសាលាដំបូងមិនអាចចាត់ទុកថាសមូហភាវូនីយកម្មជាគោលដៅពាក់ព័ន្ធមួយនៃការផ្លាស់ទីលំនៅរបស់ប្រជាជននោះទេ។ ក្នុងន័យនេះ ការដាក់ប្រជាជនជាទាសករ ហាក់ដូចជាគោលបំណងមួយក្នុងចំណោមគោលបំណងដ៏សំខាន់ៗផ្សេងទៀតនៃរបបខ្មែរក្រហម ហើយការផ្លាស់ទីលំនៅប្រជាជនគ្រាន់តែជាជំហានដំបូងតែប៉ុណ្ណោះ"[88]។

៦៣. មតិលើកប្រហើរចោលនេះ ស្មើនឹងសេចក្តីសន្និដ្ឋានលើអត្ថិភាពនៃឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃការជំនុំជម្រះ វគ្គ ២ ហើយដែលយោបល់ប្រហើរចោលនេះត្រូវបានសម្តែងឡើង ដោយមិនមានកំណត់ត្រាជើងទំព័រ ឬឯកសារយោងជាក់លាក់ដើម្បីគាំទ្រការរកឃើញណាមួយរបស់អង្គជំនុំជម្រះឡើយ។ គ្រាន់តែមតិប្រហើរចោលមួយនេះ វាជាការគ្រប់គ្រាន់ក្នុងការបង្ហាញពីភាពលំអៀងជាក់ស្តែង និង/ឬ យ៉ាងហោចណាស់ វាអាចជាមូលដ្ឋានស្របច្បាប់នៃការព្រួយបារម្ភអំពីភាពលំអៀងរបស់

[86] សូមមើលផងដែរ កថាខណ្ឌ ៧៥៣-៧៥៧ និង ១០១៣-១០១៥ (ឧបសម្ព័ន្ធ ៣)។ ឧបសម្ព័ន្ធ ២, ៤, ៥, ៦, ៨, ៩, ១០, ១១, ១៣, ១៤, ១៥ និង ១៦។

[87] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ២២៧។ សូមមើល កថាខណ្ឌ ៨១៥-៨១៧, ៨២០, ៨២៥, ៨២៧-៨៣០, ៨៣៤, ៨៣៧, ៨៣៩-៨៤៤, ១០០៥ (ឧបសម្ព័ន្ធ ៣)។ សូមមើលផងដែរ ឧបសម្ព័ន្ធ ៨, ៩, ១៣ និង ១៤។

[88] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៨២៨ (យើងជាអ្នកដាក់អក្សរដិត)។

ចៅក្រម។ មតិលើកឡើងដោយប្រហើរនេះមិនស៊ីគ្នានឹងកាតព្វកិច្ចរបស់ចៅក្រមតុលាការកំពូលដែលត្រូវសម្រេច ដោយគ្មានបុរេវិនិច្ឆ័យ លើបញ្ហានៃការដាក់ប្រជាជនជាទាសករ និងគោលបំណងនៃគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋានការងារ។

៦៤. លើសពីនេះទៀត តុលាការកំពូលបានធ្វើការសន្និដ្ឋានលើអង្គហេតុពាក់ព័ន្ធទស្សនកិច្ចតាមការដ្ឋានរបស់ ខៀវ សំផន ដែលរងការចោទប្រកាន់[89]។ តុលាការកំពូលក៏បានសម្រេចលើការចូលរួមរបស់ ខៀវ សំផន ក្នុងការបង្កើតគោលនយោបាយសេដ្ឋកិច្ច ដែលរួមបញ្ចូលទាំងគោលនយោបាយរងការចោទប្រកាន់ ដូចជានយោបាយបង្កើតសហករណ៍ និងការដ្ឋានការងារ[90] និងបានសម្រេចលើទិដ្ឋភាពទូទៅនៃផែនការសេដ្ឋកិច្ច នាឆ្នាំ១៩៧៧[91]។

៦៥. ***<u>គោលនយោបាយស្តីពីការចាត់វិធានការប្រឆាំងនឹងក្រុមជាក់លាក់នៃអតីតរដ្ឋការរបបសាធារណរដ្ឋខ្មែរ៖</u>*** តុលាការកំពូលបានសន្និដ្ឋានយ៉ាងច្បាស់ថាមានចំណុចប្រសព្វគ្នារវាងគោលនយោបាយចំពោះសត្រូវ និងគោលនយោបាយស្តីពីការចាត់វិធានការប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ៖

> "ដូចគ្នាដែរ វាហាក់ដូចជាមានការត្រួតស៊ីគ្នារវាងអ្វីដែលយើងគប្បីហៅថាគោលនយោបាយអប់រំកែប្រែសមាសភាពមិនល្អ គោលនយោបាយកម្ទេចខ្មាំង និងគោលនយោបាយស្តីអំពីការចាត់វិធានការប្រឆាំងនឹងទាហាននិងមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ។ [...] ជាថ្មីម្តងទៀត ត្រង់នេះហើយជាការបង្ហាញពីការត្រួតស៊ីគ្នារវាងគោលនយោបាយនៃការកម្ទេចខ្មាំងនិងគោលនយោបាយស្តីអំពីការចាត់វិធានការប្រឆាំងនឹងក្រុមជាក់លាក់មួយចំនួន" [92]។

[89] សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ១0២៨។

[90] សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ៨៣៨, ៨៤0-៨៤២។

[91] សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ៨៤៣។

[92] សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ២២៧។

៦៦. លើសពីនេះទៀត តុលាការកំពូលបានធ្វើការសន្និដ្ឋានទាក់ទងនឹងអំពើមនុស្សឃាតលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការដាក់បញ្ចូលអំពើនេះទៅក្នុងផែនការរួម ក្នុងអំឡុងពេលដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២៖

> "**បទបញ្ជារបស់ ប.ក.ក ឱ្យសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពាក់ព័ន្ធនឹងនឹងរយៈកាលក្រោយៗមក ហាក់ដូចជាមានសភាពខ្លាំងក្លាជាង** ប៉ុន្តែមិនមានទំនាក់ទំនងជាក់ស្តែងណាមួយជាមួយខែមេសា ឆ្នាំ១៩៧៥ ទេ"[93]។
>
> "អង្គជំនុំជម្រះតុលាការកំពូលកត់សំគាល់ថា ***ភ័ស្តុតាងកើតឡើងក្រោយព្រឹត្តិការណ៍ទួលពោធិ៍ជ្រៃមើលទៅដូចជារឹងមាំ***ជាងភ័ស្តុតាងដែលបានកើតឡើងមុនព្រឹត្តិការណ៍នេះ"[94]។

៦៧. ***គោលនយោបាយកំចាត់ខ្មាំង៖*** ជាពិសេស តុលាការកំពូលបានទាញការសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយកម្ទេចខ្មាំង៖

> "សរុបសេចក្តីមក ភ័ស្តុតាងទាក់ទងនឹងមនោគមវិជ្ជារបស់ ប.ក.ក អាចនាំឱ្យចៅក្រមអង្គសេចក្តីដែលមានហេតុផល សន្និដ្ឋានបានថាមាគ៌ាបក្សដូចដែលបានពិពណ៌នា ទោះបីវាត្រូវបានផ្សព្វផ្សាយតាមរយៈសេចក្តីថ្លែងការណ៍ជាសាធារណៈ និងវគ្គសិក្សារៀនសូត្រក៏ដោយ ក៏វាអាចបង្កើតបានជាគ្រឹះមនោគមវិជ្ជាសម្រាប់វិធានការណ៍ជាច្រើនប្រឆាំងនឹងអ្នកដែលគេគិតថាជាខ្មាំងដែរ ហើយវិធានការណ៍នេះអាចឈានចូលដល់ការកម្ទេចបំបាត់រាងកាយទៀតផង។ [...] ៩៦៧. ទាក់ទងនឹងភ័ស្តុតាងពាក់ព័ន្ធនឹងគោលជំហរទូទៅរបស់ ប.ក.ក ផ្នែកមនោគមវិជ្ជាកុម្មុយនិស្តចំពោះសត្រូវ តុលាការកំពូលបានយល់ឃើញថាវាជាការអាចជឿជាក់បានដែលថាសុន្ទរកថានិងសេចក្តីថ្លែងការណ៍របស់បក្សដូចដែលបានដកស្រង់សម្តី អាចត្រូវបានគេចាត់ទុកថាជាការដាក់មូលដ្ឋានគ្រឹះនៃគោលនយោបាយមួយដែលទំនងជាមានផែនការសម្លាប់ខ្មាំង"[95]។

---

[93] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៩៦០ (យើងជាអ្នកដាក់អក្សរដិត)។

[94] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៩៧០ (យើងជាអ្នកដាក់អក្សរដិត)។ សូមមើលផងដែរ កថាខណ្ឌ ៨៦០, ៨៨៣-៨៨៤, ៨៩១, ៩០០, ៩០២, ៩០៣, ៩០៨, ៩៣០, ៩៤៧, ៩៥១-៩៥២, ៩៥៨, ៩៦២, ៩៦៥, ៩៦៧, ៩៦៨, ៩៧១។ ឧបសម្ព័ន្ធ ៣, ៨, ៩, ១០, ១១, ១៣ និង ១៤។

[95] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៩៣៣, ៩៦៧។ សូមមើលផងដែរ កថាខណ្ឌ ៨៦០, ៨៨៣-៨៨៤, ៨៩១, ៩០០, ៩០២, ៩០៣, ៩០៨, ៩៣០, ៩៤៧, ៩៥១-៩៥២, ៩៥៨, ៩៦០, ៩៦២, ៩៦៥, ៩៦៨, ៩៧០, ៩៧១។ ឧបសម្ព័ន្ធ ៣, ៨,

៦៨. ***សេចក្តីសន្និដ្ឋានថា ខៀវ សំផន ទំនងជាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម យ៉ាងជ្រៀលជ្រៅ៖*** តុលាការកំពូលបានធ្វើការសន្និដ្ឋានទូទៅជាច្រើនអំពីតួនាទីរបស់ **ខៀវ សំផន** ក្នុងការសម្រេចផែនការរួមដែលកំណត់ទំនួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្ម ក្រោមបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២។ សេចក្តីសន្និដ្ឋានទាំងនេះទាក់ទងនឹង "តួនាទីរបស់ ខៀវ សំផន ក្នុងឋានៈជាសេដ្ឋវិទូក្នុងការសម្រេចផែនការរួម" និងជាពិសេសទាក់ទងនឹងឋានៈគាត់ជាសមាជិកនៃមន្ទីរ ៨៧០[96] និងជាអ្នកត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្ម[97]។ សេចក្តីសន្និដ្ឋានទាក់ទងផងដែរនឹងការចូលរួមចំណែករបស់គាត់ តាមរយៈការចូលរួមក្នុងការប្រជុំនយោបាយ[98] និងអប់រំ[99] និងតាមរយៈ "សេចក្តីថ្លែងការជាសាធារណៈ"[100] ការចូលរួមចំណែក "នៅក្នុងវិស័យការទូត"[101] និងតាមរយៈ "សិទ្ធិអំណាច និងឥទ្ធិពល" របស់គាត់[102]។ អាស្រ័យហេតុនេះ តុលាការកំពូលបានតម្កល់សេចក្តីសន្និដ្ឋានរបស់សាលាដំបូង ក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ ថា ខៀវ សំផន ទំនងជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងផែនការរួម[103]។ លើសពីនេះទៀត តុលាការកំពូលបានសម្រេចទុកជាមុនពី "តួនាទីរបស់ណៈកម្មាធិការមជ្ឈិម" ជាពិសេសលើកិច្ចប្រជុំថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[104] និងពី "លទ្ធិប្រជាធិបតេយ្យប្រមូលផ្តុំ"[105]។ ធាតុផ្សំរភស្តុតាងទាំងនេះត្រូវបានបដិសេធដោយម្ចាស់បណ្តឹងក្នុងក្របខណ្ឌបណ្តឹងឧទ្ធរណ៍នៃសំណុំរឿង ០០២/០២[106]។

---

៩, ១០, ១១, ១៣ និង ១៤។

[96] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០១៧។

[97] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០១៨។

[98] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០០៦, ១០១១។ សូមមើលផងដែរ កថាខណ្ឌ ១០៨៦។

[99] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០១៥។

[100] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០២២, ១០២៤។

[101] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០២៧-១០២៨។

[102] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០២៩។

[103] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០៣០។

[104] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០៤៧។

[105] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០៥០។

[106] សូមមើល ឧបសម្ព័ន្ធ ១៥។

៦៩. ***សេចក្តីសន្និដ្ឋានថា ខៀវ សំផន ដឹងឮអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត និងសេចក្តីសន្និដ្ឋានលើចេតនារបស់គាត់៖*** តុលាការកំពូលបានទាញសេចក្តីសន្និដ្ឋានលើការដឹងឮរបស់ **ខៀវ សំផន** អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០២/០១ និងសេចក្តីសន្និដ្ឋានលើចេតនារបស់គាត់។ សេចក្តីសន្និដ្ឋានទាំងនេះមានជាប់ទាក់ទងទៅនឹងការជំនុំជម្រះសំណុំរឿង ០០២/០២ ហើយក៏ត្រូវបានជំទាស់ដោយម្ចាស់បណ្តឹងជិតចិត្តដែរ[107]។

## ii. សេចក្តីសន្និដ្ឋានផ្លូវច្បាប់ដែលកំណត់ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន

៧០. ក្នុងឋានៈជាចៅក្រមអង្គច្បាប់ដែលត្រូវសម្រេចលើកំហុសអង្គច្បាប់ដែលមេធាវីការពារក្តីបានចោទប្រកាន់ តុលាការកំពូលត្រូវតែអនុវត្តការត្រួតពិនិត្យយុត្តាធិការដែលស្រដៀងគ្នានឹង "ការត្រួតពិនិត្យដោយសាលាវិនិច្ឆ័យជាន់ខ្ពស់ ដែលត្រួតពិនិត្យលើនីត្យានុកូលភាព ដែលទាក់ទងនឹងការគោរពច្បាប់នៅពេលអនុវត្តការត្រូវពិនិត្យតាមផ្លូវច្បាប់លើការវាយតម្លៃអង្គហេតុ"[108]។ ភាពលំអៀងរបស់ចៅក្រមរងបណ្តឹងជិតចិត្តនេះ ត្រូវតែវាយតម្លៃដោយផ្អែកលើការពិសោធដែលទទួលយកដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ដូចបានរៀបរាប់ខាងលើ។ វាចាំបាច់ក្នុងការបង្ហាញថា "បញ្ហានានាដែលចៅក្រម[ត្រូវ] ដោះស្រាយក្នុងបណ្តឹងឧទ្ធរណ៍លើកទីពីរនេះ ស្រដៀងគ្នានឹងបញ្ហាដែលពួកគាត់បានសម្រេចក្នុងបណ្តឹងឧទ្ធរណ៍លើកទីមួយ"[109]។

៧១. រាល់បញ្ហាអង្គច្បាប់វិនិច្ឆ័យទុកជាមុនដោយចៅក្រមរងបណ្តឹងជិតចិត្តនេះ គឺជាកត្តាកំណត់ថា ខៀវ សំផន មានទំនួលខុសត្រូវព្រហ្មទណ្ឌ។ បញ្ហាទាំងនេះទាក់ទងនឹងធាតុផ្សំសត្យានុម័ត និងអត្តនោម័តសម្រាប់ឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៃសំណុំរឿង ០០២/០២ និងទម្រង់នៃទំនួលខុសត្រូវព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទ ក៏ដូចជាការអាចព្យាករបាន និងភាពស្របច្បាប់នៃ

---

[107] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៨៣៧, ៨៣៩-៨៤២, ១០០៥-១០០៦, ១០៥៤-១០៥៥, ១០៧១-១០៧៧, ១០៧៩, ១០៨១-១០៨២, ១០៨៤, ១០៨៥-១០៩០។ សូមមើលផងដែរ ឧបសម្ព័ន្ធ ១៥។

[108] *រឿងក្តី Mancel និង Branquart តទល់នឹងប្រទេសបារាំង (បណ្តឹងលេខ 022349/06) សាលដីកា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨។*

[109] សូមមើលខាងលើ កថាខណ្ឌ ៣៨-៣៩។ *រឿងក្តី Mancel និង Branquart តទល់នឹងប្រទេសបារាំង (បណ្តឹងលេខ 022349/06) សាលដីកា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៣៧។*

ធាតុផ្សំទាំងនេះ។ បញ្ហាទាំងនេះគឺជាចំណុចស្នូលនៃបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំរឿង ០០២/០២ និងមានឥទ្ធិពលគន្លឹះលើលទ្ធផលចុងក្រោយនៃសំណុំរឿងនេះ។

៧២. តុលាការកំពូលបានសម្រេចរួចហើយ លើធាតុផ្សំក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[110] យុត្តាធិការពេលវេលា[111] ភាពអាចប្រមើលមើលទុកជាមុនបាន និងគោលការណ៍នីត្យនុកូលភាព[112] ធាតុផ្សំអត្តនោម័តនៃមនុស្សឃាត ក្រោមទម្រង់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[113] និងក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម[114]។ បញ្ហាច្បាប់ទាំងនេះគឺជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២ និងជាចំណុចសំខាន់ក្នុងការសម្រេចលើទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ **ខៀវ សំផន** ចំពោះឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២[115]។

៧៣. ក្នុងសំណុំរឿង ០០២/០១ ចៅក្រមមិនត្រឹមតែអនុវត្តច្បាប់យុត្តិសាស្ត្រដដែលម្តងទៀតនោះទេ ប៉ុន្តែថែមទាំង**បានទាញ**ការសន្និដ្ឋានពិស្តារជាច្រើនដែលប្រាសចាកពីលទ្ធិច្បាប់[116]។ ជាថ្មីម្តងទៀត លោក **ខៀវ សំផន** មិនត្រឹមតែមិនត្រូវបានវិនិច្ឆ័យដោយសាលាក្តីមិនលំអៀងដែលជាសិទ្ធិជាមូលដ្ឋានរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែតាមអ្វីដែលបានកើតឡើងជាក់ស្តែង សិទ្ធិប្តឹងឧទ្ធរណ៍របស់គាត់ក៏នឹងបាត់បង់ទាំងស្រុង ប្រសិនបើចៅក្រមតុលាការកំពូលមិនព្រមដកខ្លួន។

---

[110] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៧១១-៧៣២, ៧៣៨-៧៤០, ៧៤៤-៧៤៩, ៧៥៣-៧៥៤។ សូមមើលផងដែរ ឧបសម្ព័ន្ធ ៣។

[111] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ២១៣-២២១,២២៩, ៧៤១។ សូមមើលផងដែរ ឧបសម្ព័ន្ធ ១។

[112] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៥៧៦, ៥៨៩, ៧៦១-៧៦២, ៧៦៥ (សូមមើល ឧបសម្ព័ន្ធ ១ និង ៧)។ ១០៩៣ និង ១០៩៥ (សូមមើល ឧបសម្ព័ន្ធ ១២)។

[113] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៣៩០-៤១០, ៥១៦, ៧៦៥។ សូមមើល ឧបសម្ព័ន្ធ ៧។

[114] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៧៧៣-៧៨៩, ៨០៧-៨១០, ៨១៤-៨១៧, ៨៥៧, ៨៦០, ៩៨០, ៩៨៤, ១០៥៣-១០៥៥។ សូមមើល ឧបសម្ព័ន្ធ ១២។

[115] សូមមើល ឧបសម្ព័ន្ធ ១, ២, ៧ និង ១២។

[116] សូមមើល ឧបសម្ព័ន្ធ ១, ២, ៧ និង ១២។

៧៤. វាមិនមែនជាការទាមទារបណ្តឹងឧទ្ធរណ៍ចំពោះមុខសាលាវិនិច្ឆ័យជាន់ខ្ពស់ដែលមិនមានវត្តមាននៅក្នុងក្របខណ្ឌនៃ **អ.វ.ត.ក** នោះទេ។ ប៉ុន្តែ វាជាការទាមទារសុំឲ្យសង្គ្រោះសិទ្ធិពិតជាក់ស្តែងរបស់ **ខៀវ សំផន** ក្នុងការទទួលបានការជំនុំជម្រះសេចក្តីដោយតុលាការពីរថ្នាក់ខុសគ្នា។

៧៥. មានភាពលំអៀងយ៉ាងពិតប្រាកដ ហើយយ៉ាងហោចណាស់ក៏មានការព្រួយបារម្ភស្របច្បាប់អំពីភាពលំអៀងរបស់ចៅក្រមរងបណ្តឹងជិតចិត្ត ដែលបានផ្តន្ទាទោស **ខៀវ សំផន** នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ ព្រមទាំងបានទាញការសន្និដ្ឋានមិនត្រឹមតែលើអង្គហេតុនៃសំណុំរឿង ០០២/០២ ដែលកំណត់ទំនួលខុសត្រូវរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានទាញការសន្និដ្ឋានលើបញ្ហាច្បាប់ស្រដៀងគ្នាទៀត។

## ៣.៣. __អត្ថិភាពនៃភាពលំអៀងផ្អែកលើការសន្និដ្ឋានខុសនៅក្នុងសាលដីកាសំណុំរឿង ០០២/០១__

៧៦. លើសពីនេះទៅទៀតអត្ថិភាពនៃភាពលំអៀង និង/ឬអាការៈនៃភាពលំអៀងរបស់ចៅក្រមរងបណ្តឹងជិតចិត្តទាំងប្រាំមួយរូប ស្តែងចេញពីការសន្និដ្ឋានខុសរបស់ពួកគាត់នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ។

៧៧. តុលាការកំពូលបានទទួលស្គាល់ថាអាចបង្កើតភាពលំអៀងឬអាការៈនៃភាពលំអៀងដូចនេះ៖

> "ជាពិសេសដោយផ្អែកលើសេចក្តីប្រកាសដែលធ្វើឡើងដោយតុលាការនេះនៅក្នុងក្របខណ្ឌនៃសំអាងហេតុនៃសេចក្តីសម្រេចមួយ។ (...) មួយក្រឡេកភ្នែក វិធីសាស្ត្របែបនេះមិនមែនដើម្បីបង្ហាញថាតើ [តុលាការនេះ] ភាន់ច្រឡំនោះទេ ប៉ុន្តែដើម្បីបង្ហាញថាតើតាមរយៈសំអាងហេតុរបស់តុលាការនេះ វាមានលេចឡើងនូវអ្វីដែលបង្ហាញថាតុលាការនេះលំអៀងឬអត់"[117]។

៧៨. ក្រុមប្រឹក្សាជំនុំជម្រះពិសេសដែលបានកាត់សេចក្តីលើការចោទប្រកាន់អំពីភាពលំអៀងពនៃសាលក្រម សំណុំរឿង ០០២/០១ បានបញ្ជាក់ថាចាំបាច់ត្រូវបង្ហាញថា៖

---

[117] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ១១២។ សូមមើលផងដែរ ឯកសារយោងទៅនឹងយុត្តិសាស្ត្រអន្តរជាតិ នៅជើងទំព័រ ២៤៣ និង ២៤៤។

"សេចក្តីសម្រេចរងបណ្តឹងឧទ្ធរណ៍នេះបណ្តាលមកពី ឬអាចត្រូវបានគេយល់ដោយសមហេតុផលថាជាលទ្ធផលនៃភាពលំអៀងរបស់ចៅក្រមជាជាងការអនុវត្តជាក់ស្តែងនៃច្បាប់ដែលអាចមានការបកស្រាយឬការវាយតម្លៃអង្គហេតុច្រើនលើសពីមួយ។ ពិតណាស់ សេចក្តីសម្រេចទាំងអស់របស់តុលាការដែលបានដកស្រង់ដើម្បីគាំទ្រការចោទប្រកាន់អំពីភាពលំអៀង ត្រូវតែត្រូវយកមកពិនិត្យ ប៉ុន្តែគោលបំណងនៃការពិនិត្យនេះគឺមិនមែនដើម្បីរកឲ្យឃើញកំហុសនោះទេ។ គឺពិនិត្យដើម្បីកំណត់ថាតើតាមរយៈកំហុសជាយថាហេតុ វាស្តែងឲ្យឃើញថាចៅក្រមពិតជាលំអៀងមែន ឬវាស្តែងឲ្យឃើញថាអ្នកសង្កេតការណ៍សមហេតុផលម្នាក់ដែលដឹងច្បាស់អំពីកាលៈទេសៈពាក់ព័ន្ធ អាចព្រួយបារម្ភថាចៅក្រមលំអៀង ដោយមានហេតុផល ឬអត់"[118]។

៧៩. ក្នុងករណីនេះ នៅក្នុងសាលដីកា ០០២/០១ ចៅក្រមរងបណ្តឹងជិតចិត្តទាំងប្រាំមួយរូប បានប្រព្រឹត្តកំហុសជាច្រើនដែលមិនមែនជាលទ្ធផលនៃការអនុវត្តច្បាប់ដែលមានការបកស្រាយលើសពីមួយ។ កំហុសទាំងនេះប្រាកដជាមិនមែនជាលទ្ធផលនៃការចៃដន្យ ហើយវាបង្ហាញពីភាពលំអៀងរបស់ចៅក្រម។ ភាពលំអៀងនេះស្តែងឡើងយ៉ាងច្បាស់ គ្រាន់តែតាមរយៈការសន្និដ្ឋានខុសទាំងឡាយលើគោលការណ៍នីត្យានុកូលភាព (១) លើធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់អំពើមនុស្សឃាត (២) លើសហឧក្រិដ្ឋកម្មរួម (៣) និងលើការកំណត់ប្រភេទបទល្មើស (៤) ។ ដូច្នេះ ការកែបំភ្លៃច្បាប់លើបញ្ហាទាំងនេះ គឺជាមធ្យោបាយតែមួយគត់ដើម្បីធ្វើយ៉ាងណាផ្តន្ទាទោស ខៀវ សំផន ឱ្យខាងតែបាន។

### ៣.៣.១. <u>ការសន្និដ្ឋានខុសលើគោលការណ៍នីត្យានុកូលភាព</u>

---

[118] សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជិតចិត្ត ឯកសារ E314/12/1 កថាខណ្ឌ ៣៦។ សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត ឯកសារ E55/4 កថាខណ្ឌ ១៣ ៖ "វាមិនមែនមានលក្ខណៈគ្រប់គ្រាន់ទេក្នុងការចោទប្រកាន់អំពីកំហុសលើអង្គច្បាប់ណាមួយ ប្រសិនជាមានយកមកធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់អំពីភាពលម្អៀង ដោយផ្អែកលើសេចក្តីសម្រេចរបស់ចៅក្រមនោះ។ អ្វីដែលអ្នកដាក់បណ្តឹងដាក់បង្ហាញគឺថា សេចក្តីសម្រេចពិតជាបណ្តាលឲ្យមាន ឬត្រូវបានគេយល់ឃើញដោយសមហេតុផលថាមានបុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង និងជាសេចក្តីសម្រេចដែល**មិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ដោយសុក្រឹត្យ ពោលគឺការបកស្រាយច្បាប់ដោយអត្តនោម័ត នៅពេលដែលច្បាប់នោះអាចបកស្រាយបានច្រើនរបៀប ឬជាសេចក្តីសម្រេចដែលមិនពិចារណាវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានា។ ការខ្វែងគំនិតលើខ្លឹមសារនៃសេចក្តីសម្រេច គឺជាបញ្ហាសម្រាប់ការប្តឹងឧទ្ធរណ៍ មិនមែនជាបញ្ហាសម្រាប់ដាក់បណ្តឹងជិតចិត្តឡើយ។**" (យើងជាអ្នកដាក់អក្សរដិត)។

៨០. នៅក្នុងវិធីសាស្ត្រច្បាប់ស្តីពីការដាក់ទណ្ឌកម្ម ចៅក្រមរងបណ្តឹងផិតចិត្តបានបំបាត់សារធាតុនៃគោលការណ៍នីត្យនុកូលភាព ដោយលើកវាឡើងដើម្បីតែបង្គ្រប់កិច្ចតែប៉ណ្ណោះ។ នៅក្នុងសំណុំរឿង ឌុច ស្របតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការកំពូលបានតម្រូវថា "**លក្ខណៈវិនិច្ឆ័យដែលកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្ម**" និង"**ទម្រង់នៃការទទួលខុសត្រូវ**" ត្រូវតែមានចែងដោយច្បាប់ក្នុងសម័យអង្គហេតុ ដែលអាចព្យាករណ៍បាន និងអាចយល់ដឹងបាន[119]។ នៅក្នុងសំណុំរឿង ០០២/០១ តុលាការកំពូលបានប្រាសចាកពីយុត្តិសាស្ត្រនេះ ដោយពិចារណាថាវាជាការគ្រប់គ្រាន់កាលណាមានឧក្រិដ្ឋកម្ម ឬទម្រង់នៃទំនួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យអង្គហេតុ និងកាលណាជនជាប់ចោទមានមុខតំណែងខ្ពស់[120]។ តុលាការកំពូលបានអះអាងថាលក្ខខណ្ឌនៃភាពអាចព្យាករណ៍បានត្រូវបានបំពេញ ប្រសិនបើជនជាប់ចោទដឹងថាអំពើរបស់គាត់មានលក្ខណៈឧក្រិដ្ឋ "ក្នុងន័យដែលមនុស្ស**ទូទៅ**អាចយល់បាន **ដោយមិនចាំបាច់យោងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយ** ដែលនេះជាលក្ខណៈវិនិច្ឆ័យសម្រាប់ "[ឧក្រិដ្ឋកម្ម] ធ្ងន់ធ្ងរបំផុតនានាមិនដែលមិនធ្លាប់បានចុះបញ្ជី"[121]។ មេធាវីការពារក្តីសូមយោងទៅលើអំណះអំណាងដែលបានលើកឡើង នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ (សូមមើលកថាខណ្ឌ ៣៣១-៣៨០) ។

៨១. ការវិភាគភាន់ច្រលំនិងលំអៀងនេះត្រូវបានគាំទ្រ ដោយការអនុវត្តបែបឱកាសនិយមនៃ "គោលការណ៍នីត្យនុកូលភាព" ថ្មីនេះ។ ជាពិសេស ចៅក្រមខកខានមិនបានពិចារណាលើភាពអាចព្យាករណ៍ទុកជាមុនបាន និងការអាចយល់ដឹងបានអំពីធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់អំពើមនុស្សឃាត និងសហឧក្រិដ្ឋកម្មរួម[122]។ ប្រការនេះមិនមែនជារឿងតូចតាចទេ។

---

[119] សាលដីកា ឌុច ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ **001-F28** កថាខណ្ឌ ៩៧។ សូមមើលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (០០២/០២) **E457/6/4** កថាខណ្ឌ ៣០០-៣៣០។

[120] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៦១-៧៦២, ៧៦៤។

[121] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៦២ (យើងជាអ្នកដាក់អក្សរដិត), កថាខណ្ឌ ៧៦៥។

[122] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៦៥ ៖ "ដូច្នេះ អ្វីដែលតម្រូវនោះ គឺមិនមែនជាការពិចារណាអំពីពាក្យពេចន៍បច្ចេកទេសក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែនៅត្រង់ ថាតើ**ជាទូទៅ**អាចយល់ដឹងជាមុនបានថា អំពើនោះអាចតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា។ **អាស្រ័យហេតុនេះ ពុំមានភាពចាំបាច់ត្រូវបង្ហាញថា អាចយល់ដឹងជាមុនបានថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចកើតឡើងនៅក្នុងកាលៈទេសៈនៃការប្រព្រឹត្តដោយចេតនាប្រយោល** *(dolus*

## ៣.៣.២. ការសន្និដ្ឋានខុសដែលបន្ទាបកម្រិតធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាមនុស្សឃាតមកត្រឹមចេតនាប្រយោល

៨២. តុលាការកំពូលបានសម្រេចយកដោយភាន់ច្រឡំ និងលំអៀង នូវនិយមន័យនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់អំពីមនុស្សឃាត "ក្នុងន័យទូលំទូលាយ" ដែលក្តោបបញ្ចូលទាំងចេតនាប្រយោល[123]។ សេចក្តីសន្និដ្ឋានផ្លូវច្បាប់របស់ចៅក្រមរងបណ្តឹងជិតចិត្តនេះបង្ហាញយ៉ាងច្បាស់នូវការបន្ទាបបន្ថោកគោលការណ៍ដ៏សំខាន់នៃការបកស្រាយយ៉ាងតឹងរ៉ឹងនៅក្នុងរឿងព្រហ្មទណ្ឌ។

៨៣. និយមន័យនេះរំលោភលើគោលការណ៍ច្បាប់ ពីព្រោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាតកាលពីឆ្នាំ១៩៧៥ កម្រិតត្រឹមតែចេតនាសម្លាប់ប៉ុណ្ណោះ។ ដើម្បីបន្ទាបលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិ ចៅក្រមបានប្រើឆន្ទានុសិទ្ធិខ្លួនខុសច្បាប់ ដោយជ្រើសរើស និងផ្អែកលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួនដែលតាក់តែងឡើងក្រោយសម័យអង្គហេតុ និងដោយផ្អែកលើការបកស្រាយខុសនៃ "រឿងក្តីវេជ្ជបណ្ឌិត" ហើយបានយោងទៅច្បាប់ជាតិដែលត្រូវបានតាក់តែងឡើងនៅក្រោយឆ្នាំ១៩៧៥។ មេធាវីការពារក្តីសូមយោងទៅលើអំណះអំណាងដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ (សូមមើល ៣៩៥-៤២៩) ។

៨៤. ដោយហេតុថាពុំមានភស្តុតាងនៃចេតនាដោយផ្ទាល់ក្នុងការសម្លាប់[124] នេះគឺជាមធ្យោបាយតែមួយគត់ដើម្បីដាក់ទណ្ឌកម្មលើជនជាប់ចោទ ចំពោះការស្លាប់ដែលបានកើតឡើងក្នុងកំឡុងពេលផ្លាស់ទីលំនៅប្រជាជន។ ទោះយ៉ាងនេះក្តី ក៏វាមិនគ្រប់គ្រាន់ដែរ។ ចៅក្រមក៏ខំប្រឹងបញ្ចូលចេតនាប្រយោលក្នុងនិយមន័យនៃទម្រង់ទំនួលខុសត្រូវ ដើម្បីផ្តន្ទាទោសឱ្យខាងតែបាន។

---

***eventualis)* ដែលផ្ទុយពីចេតនាផ្ទាល់ *(dolus directus)* នោះទេ។**" (យើងជាអ្នកដាក់អក្សរដិត) កថាខណ្ឌ ១០៩៣។

[123] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥១០។

[124] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៣៨, ៥៥៨។

### ៣.៣.៣. ការសន្និដ្ឋានខុសលើសហឧក្រិដ្ឋកម្មរួម ដោយបន្ទាបលក្ខខណ្ឌតម្រូវនៃចេតនាអត្តនោម័តិមកត្រឹមចេតនាប្រយោល

៨៥. តុលាការកំពូលបានប្រព្រឹត្តកំហុសអង្គច្បាប់ និងបានបង្ហាញពីភាពលំអៀងជាក់ស្តែង តាមរយៈការអះអាងថាផែនការរួមផ្ទាល់នេះពុំមានចរិតឧក្រិដ្ឋទេ ប៉ុន្តែ វាអាចត្រូវបានរកឃើញថាជាផែនការឧក្រិដ្ឋ ហើយអាចបំពេញលក្ខខណ្ឌតម្រូវនៃសហឧក្រិដ្ឋកម្មរួម-ទម្រង់ទី I ប្រសិនបើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត កើតចេញពី"ការមិនអើពើ និងយថាហេតុដែលអាចកើតឡើង"[125]។

៨៦. ចៅក្រមរងបណ្តឹងដិតចិត្តមិនបានជ្រើសការបកស្រាយមួយក្នុងចំណោមការបកស្រាយជាច្រើនដែលអាចធ្វើបាននោះទេ ហើយថែមទាំងបានបដិសេធចោលដោយគ្មានសំអាងហេតុនូវយុត្តិសាស្ត្រច្បាស់លាស់ដែលមិននាំឱ្យមានការភាន់ច្រឡំ ដើម្បីជ្រើសរើយកចេតនាប្រយោលជាលក្ខខណ្ឌតម្រូវក្នុងការគាំទ្រដល់ចរិតឧក្រិដ្ឋនៃផែនការរួម[126]។ តុលាការកំពូលបានទម្លាក់ចោលរាល់វិធានច្បាប់ដែលអាចអនុវត្តបាន ហើយបានបង្កើតសហឧក្រិដ្ឋកម្មរួមកូនកាត់មួយ ដែលបូកបញ្ចូលគ្នានូវធាតុផ្សំនៃអំពើឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មទម្រងទី I និងធាតុផ្សំនៃចេតនាឧក្រិដ្ឋទម្រង់ទី III ដែលមិនអាចអនុវត្តបាននៅ អ.វ.ត.ក។ មេធាវីការពារក្តីសូមយោងទៅលើអំណះអំណាងដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ (សូមមើល ៤៣០-៥១៦) ។ ការបង្កើតយុត្តិសាស្ត្រដែលមិនធ្លាប់មានពីមុនមកនេះផ្ទុយនឹងយុត្តិសាស្ត្របង្កើតឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែលអនុវត្តសហឧក្រិដ្ឋកម្ម។ ចៅក្រមរងបណ្តឹងដិតចិត្តមិនបានបញ្ជាក់ពីឯកសារយោងណាមួយ ដើម្បីគាំទ្រការវិភាគរបស់ខ្លួនទាល់តែសោះ៖ មិនមានកំណត់ត្រាជើងទំព័រ សម្រាប់គាំទ្រកថាខណ្ឌទាំងពីរនេះទេ។ ប្រការនេះធ្វើឱ្យទម្រង់នៃទំនួលខុសត្រូវនេះអស់តម្លៃ។

៨៧. ក្នុងផ្នែកសំអាងហេតុនៃសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបដិសេធការបង្កើតថ្មីនេះយ៉ាងត្រឹមត្រូវថា៖

---

[125] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨០៩។

[126] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨០៨-៨០៩។

"ចេតនាប្រយោលដែលជាធាតុផ្សំបង្កើតជានិយមន័យនៃសហឧក្រិដ្ឋរួមទម្រង់ទីIII ពុំអាចប្រែក្លាយជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I បានទេ។ [...] អាស្រ័យហេតុនេះ ស្របតាមសេចក្តីសន្និដ្ឋាននានារបស់មេធាវី ខៀវ សំផន អង្គជំនុំជម្រះយល់ឃើញថាកម្រិតធាតុផ្សំចេតនាដែលតម្រូវឱ្យមាននៅក្នុងសហឧក្រិដ្ឋកម្មទម្រង់ទី I គឺចេតនាប្រយោល"[127]។

"អង្គជំនុំជម្រះមើលឃើញថាគ្មានហេតុផលអ្វីដែលខ្លួនត្រូវងាកចេញពីយុត្តិសាស្ត្រជាប់លាប់ស្ថិតស្ថេរនៃតុលាការចំពោះកិច្ចក្នុងការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I"[128]
។

៨៨. យ៉ាងជាក់ស្តែង ក្នុងពេលកាត់សេចក្តីលើបណ្តឹងឧទ្ធរណ៍ ប្រការដែលចៅក្រមតុលាការកំពូលដដែលបែរជាមករិនិច្ឆ័យលើសហឧក្រិដ្ឋកម្មរួម ចោទជាបញ្ហាចំពោះម្ចាស់បណ្តឹងជិតចិត្ត។

៨៩. ការបកស្រាយយ៉ាងទូលាយនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I គឺជាមធ្យោបាយតែមួយគត់ដើម្បីឈានទៅដល់ការដាក់បន្ទុកលើផែនការរួម។ នៅក្នុងការវិភាគអង្គហេតុរបស់ពួកគាត់ ចៅក្រមរងបណ្តឹងជិតចិត្តគ្រប់រូបបានបង្ខិលតម្រែតម្រង់សហឧក្រិដ្ឋរួមដ៏យឺតដូចកៅស៊ូនេះ ធ្វើយ៉ាងណាដើម្បីបញ្ចូលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទៅក្នុងវិសាលភាពនៃផែនការរួម[129]។

៩០. ជាឧទាហរណ៍ ដើម្បីបញ្ចូលក្នុងផែនការរួម នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាតក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ ចៅក្រមបានផ្អែកយ៉ាងច្បាស់ក្រឡែតលើចេតនាប្រយោល ចំពោះការស្លាប់ដែលបានកើតឡើង ដោយសារលក្ខខណ្ឌនៃការ

---

[127] សាលក្រម [សំណុំរឿង ០០២/០២] ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465**, កថាខណ្ឌ ៣៧១៥។ សូមមើល កថាខណ្ឌ ៣៧១៤, ៣៩២១ ("ដោយរំឭកថា សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់មូលដ្ឋាន មិនស្របទៅនឹងចេតនាដោយប្រយោលទេ") ។

[128] សាលក្រម [សំណុំរឿង ០០២/០២] ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** ជើងទំព័រ ១២៣៨៦។

[129] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៨៤៩។ បើតាមការពិចារណារបស់ចៅក្រម គេត្រូវបង្ហាញជាមុនពីអត្ថិភាពនៃនយោបាយមួយ ហើយបន្ទាប់មក ត្រូវកំណត់ឧក្រិដ្ឋកម្មដែល "ស្ថិតនៅក្នុងគោលបំណងរួម ក្នុងន័យថា" "គោលនយោបាយពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ត្រូវចាត់ជា ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ ដែរ ឬយ៉ាងណា និងអនុវត្តតាមគោលការណ៍ដែលបានកំណត់ខាងលើ" ។

ជម្លៀស[130] និងដោយមូលហេតុមានការសម្លាប់ជនស៊ីវិល[131]។ ចំពោះការប្រហារជីវិតអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចៅក្រមផ្នែកទាំងស្រុងលើការសន្និដ្ឋានផ្ទាល់ខ្លួនដោយគ្មានភស្តុតាងគាំទ្រ ក្នុងន័យនេះ៖ "យោងតាមកាលៈទេសៈជុំវិញការជម្លៀសចេញពីភ្នំពេញ វា**អាចគួរឲ្យជឿបាន**ថាមានទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានគេសម្លាប់ ទាំងពុំមានបញ្ជាឲ្យធ្វើបែបនេះ"[132]។ ដូចគ្នាដែរ សម្រាប់ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ តុលាការកំពូលបានបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅក្នុងផែនការរួម ដោយផ្អែកទាំងស្រុងយ៉ាងច្បាស់លើភវនីយភាព ដែលថាប្រជាជនរងការជម្លៀសបានស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅនេះ[133]។

៩១. ដូច្នេះ តុលាការកំពូលបានប្រើប្រាស់សហឧក្រិដ្ឋកម្មរួមកូនកាត់របស់ខ្លួនជាឧបករណ៍ដ៏សំខាន់ ក្នុងផ្នែកសម្រេចសេចក្ដីផ្ដន្ទាទោស។ ទម្រង់នៃទំនួលខុសត្រូវដ៏ទន់ជ្រាយស្រាប់នេះត្រូវបានលាតសន្ធឹងដល់កម្រិតអតិបរមាដើម្បីអាចឱ្យមានការផ្ដន្ទាទោសព្រហ្មទណ្ឌនេះ។

៩២. គឺមានតែតាមរយៈការបកស្រាយទូលាយនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីI និងធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាតប៉ុណ្ណោះ ដែលចៅក្រមរងបណ្ដឹង

---

[130] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨៥៣ ៖ នេះគឺដោយសារមានការបង្ហាញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមមានដូចជា ថ្នាក់ដឹកនាំបក្សបានដឹងអំពីលក្ខខណ្ឌចំពោះអ្នកដែលត្រូវជម្លៀស រួមទាំងអ្នកដែលងាយទទួលរងគ្រោះបំផុតនោះនឹងត្រូវទទួលរងទុក្ខវេទនា និងជាពិសេស អ្នកដែលងាយទទួលរងគ្រោះបំផុត**នឹងត្រូវ**ស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសនោះ។ ។

[131] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨៥៧ ៖ តុលាការកំពូលបានវិនិច្ឆ័យថាគោលបំណងរួមបានបញ្ចូលទាំងការសម្លាប់ជនស៊ីវិល នៅក្នុងពេលជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ដោយសម្អាងតែទៅលើលក្ខខណ្ឌនៃការជម្លៀស (អវត្តមាននៃមធ្យោបាយធានានូវសុខុមាលភាពអ្នកដែលត្រូវជម្លៀស) ដែលស្ដែងឱ្យឃើញថាគោលបំណងរួម "រំពឹងទុក" ថាកងទ័ពអាចនឹងប្រើប្រាស់ អំពើហិង្សាសម្លាប់ បើពួកគេជួបនឹងការចចេសរឹងរូសណា ពីព្រោះ ជាការច្បាស់ណាស់ដែលថា "គោលបំណងរួមបានរួមបញ្ចូល**ការរំពឹងទុក**នូវការប្រើប្រាស់អំពើហិង្សា ដែលបណ្ដាលឱ្យស្លាប់ដោយកងទ័ពដែលត្រូវទទួលភារកិច្ចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ប្រសិនបើមានការចចេសរឹងរូសណាមួយនោះ។" (យើងជាអ្នកដាក់អក្សរដិត)។

[132] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨៦០ (យើងជាអ្នកដាក់អក្សរដិត)។ តុលាការកំពូលសន្និដ្ឋានថា ការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាផ្នែកមួយនៃគោលបំណងរួម "ដោយប្រយោល" ។

[133] សាលដីកា ០០២/០១ ឯកសារ F36 កថាខណ្ឌ ៨៦៨។ តុលាការកំពូលសន្និដ្ឋានថាគោលនយោបាយផ្លាស់ទីលំនៅប្រជាជន "បានរួមបញ្ចូលដោយប្រយោល" នូវបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ជិតចិត្តអាចរកឃើញថា ខៀវ សំផន មានទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល នៅក្នុងសំណុំរឿង ០០២/០១។ ចេតនាឧក្រិដ្ឋត្រូវបានបន្ទាបទៅដល់កម្រិតក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ទី III (ដែលមិនអនុវត្តចំពោះមុខ អ. វ. ត. ក)។ ទង្វើនេះរំលោភគោលការណ៍ទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល។ ការបន្ទាបចេតនាឧក្រិដ្ឋដែលបង្កគ្រោះថ្នាក់ និងមិនធ្លាប់មានពីមុនមកនេះ គឺចំជាភស្តុតាងនៃការតាក់តែងកាត់កងតម្រឹមច្បាប់ឲ្យសមល្មមនឹងផ្តន្ទាទោស ខៀវ សំផន បាន។ អាស្រ័យហេតុនេះ មេធាវីការពារក្តីអាចអះអាងបានថា ចៅក្រមមានភាពលំអៀងជាក់ស្តែង ឬយ៉ាងហោចណាស់ ក៏បានបង្ហាញអាការៈនៃភាពលំអៀងរបស់ខ្លួន ហើយរាល់ទង្វើរបស់ពួកគាត់គាំទ្រដល់ការដកខ្លួនចេញរបស់ពួកគាត់។

## ៣.៣.៤. សេចក្តីសន្និដ្ឋានមិនត្រឹមត្រូវអំពីការកំណត់ប្រភេទបទល្មើសឡើងវិញ

៩៣. ដើម្បីធានាបាននូវការតម្កល់ការផ្តន្ទាទោសលោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត បើទោះជាអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសទាំងអស់នេះក៏ដោយ តុលាការកំពូលនៅតែព្យាយាមដាក់បញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មជាអតិបរមា ជាពិសេស ឧក្រិដ្ឋកម្មដែលបណ្តាលឲ្យមានមនុស្សស្លាប់។ ចេតនារបស់តុលាការកំពូលមិនទាន់លេចឡើងច្បាស់ទេ ពេលតុលាការកំពូលបានជូនដំណឹងដល់ភាគីថា ខ្លួនអាចពិចារណាកែប្រែបទចោទ មុនពេលបើកសវនាការលើបណ្តឹងសាទុក្ខ។ ប៉ុន្តែ ចេតនានេះបានក្លាយជាច្បាស់ក្រឡែត ពេលអានសាលដីកា។

៩៤. ពេលកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ តុលាការកំពូលបានជូនដំណឹងដល់ភាគីថា ខ្លួនអាចពិចារណាកែប្រែបទចោទ ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទទៅជាការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម សម្រាប់បទឧក្រិដ្ឋទាំងអស់ ដែលខ្លួនអាចនឹងសម្រេចតម្កល់ការដាក់ពិរុទ្ធភាព។ ចំពោះឧក្រិដ្ឋកម្មខ្លះ លោក ខៀវ សំផន ត្រូវបានបញ្ជូនទៅជំនុំជម្រះ រួចប្រកាសថាជាប់ពិរុទ្ធ ដោយផ្អែកតែលើទម្រង់នៃការទទួលខុសត្រូវផ្សេងក្រៅពីសហឧក្រិដ្ឋកម្មរួម (ទម្រង់នៃការទទួលខុសត្រូវប្រយោល ដូចជា ការរៀបចំផែនការ ការញុះញង់ និងការជួយជំរុញ)៖

- ការសម្លាប់រង្គាល នៅដំណាក់កាលទីមួយនៃការជម្លៀសប្រជាជន
- ការសម្លាប់រង្គាល នៅដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន

- អំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ នៅដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន
- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅទួលពោធិ៍ជ្រៃ[134]។

៩៥. ដោយយោងលើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលតាមរយៈនោះ ជនជាប់ចោទមានសិទ្ធិទទួលបានការជូនដំណឹងពីការកំណត់ប្រភេទបទល្មើស និងអាចពិភាក្សាដេញដោលចំពោះមុខបាន[135] តុលាការកំពូលបានផ្តល់លទ្ធភាពឲ្យភាគីដាក់សារណា ក្នុងរយៈពេលខ្លីបំផុត[136]។

៩៦. ក្នុងសេចក្តីសន្និដ្ឋានលើប្រធានបទនេះ[137] មេធាវីការពារក្តីបានពន្យល់ថា តុលាការកំពូលមិនអាចធ្វើការកែប្រែបទចោទ តាមការគ្រោងទុកបានទេ ដោយសារតែហេតុផលជាច្រើន។ ជាដំបូង ដោយរំលោភលើវិធាន ១១០(២) នៃវិធានផ្ទៃក្នុង តុលាការកំពូលបានបន្ថែមធាតុផ្សំថ្មី (គោលបំណង និងចេតនារួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម) ដែលមិនបានដាក់ជូនឲ្យអង្គជំនុំជម្រះសម្រេច[138]។ បន្ទាប់មក តុលាការកំពូលបានរុញច្រានជោគវាសនាលោក ខៀវ សំផន ឲ្យធ្លាក់ក្នុងស្ថានភាពកាន់តែអាក្រក់ ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដោយរំលោភលើ "គោលការណ៍មិនធ្វើឲ្យម្ចាស់បណ្តឹងធ្លាក់ក្នុងស្ថានភាពអាក្រក់ជាងមុនពេលប្តឹង បើប្តឹងតែម្នាក់ឯង" *(non reformatio in peius)* ដែលត្រូវបានផ្តល់សុពលភាពដោយអត្ថបទច្បាប់ជាធរមាន នៅចំពោះមុខ អ.វ.ត.ក (ការដំឡើងទម្រង់នៃការទទួលខុសត្រូវប្រយោលទៅជាទម្រង់នៃការទទួលខុសត្រូវផ្ទាល់ បណ្តាលឲ្យបង្កើនការទទួលខុសត្រូវព្រហ្មទណ្ឌ និងពិរុទ្ធភាពជាទូទៅ)[139]។ ជាចុងក្រោយ តុលាការកំពូលបានសម្រេចជាលើក

---

[134] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ ឯកសារ **F30** ("ដីកា **F30**") ។

[135] ដីកា **F30** ទំព័រ ៤ និង ជើងទំព័រ ១១។

[136] ដីកា **F30** ទំព័រ ៦។ ភាគី ដែលកាលនោះ កំពុងតែឡើងសវនាការ ក្នុងសំណុំរឿង ០០២/០២ មានពេលត្រឹម ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ (គឺតិចជាងមួយខែ) ដើម្បីដាក់សេចក្តីសង្កេតជាលាយលក្សណ៍អក្សរជាពីរភាសា ដោយពុំអាចពន្យារពេលបានឡើយ។ សំអាងហេតុចម្លើយអាចបង្ហាញជូនសវនាការ ដែលគ្រោងទុក ពីថ្ងៃទី១៦ ដល់ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយមិនត្រូវឲ្យលើសពីពេលកំណត់សម្រាប់ប្រធានបទ "ឧក្រិដ្ឋកម្ម" ឬ "ការទទួលខុសត្រូវ" ឡើយ។

[137] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីការកែប្រែបទចោទជាយថាហេតុ នៅដំណាក់កាលបណ្តឹងសាទុក្ខ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ **F30/5** ("សេចក្តីសន្និដ្ឋាន **F30/5**")។

[138] សេចក្តីសន្និដ្ឋាន **F30/5** កថាខណ្ឌ ៤-១២ និង ១៨-២៧។

[139] សេចក្តីសន្និដ្ឋាន **F30/5** កថាខណ្ឌ ៤-១២ និង ២៨-៣២។

ទីមួយលើការទទួលខុសត្រូវរបស់លោក ខៀវ សំផន ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ (ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ដោយរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយតុលាការពីរថ្នាក់[140]។

៩៧. ក្នុងសាលដីកា តុលាការកំពូលមិនបានបញ្ជាក់ទាល់តែសោះពីការកែប្រែទម្រង់នៃការទទួលខុសត្រូវតាមការគ្រោងទុក មុនពេលបើកសវនាការ។ តុលាការកំពូលគ្រាន់តែលើកឡើងក្នុងប្រវត្តិនីតិវិធីថា ខ្លួនបានជូនដំណឹងដល់ភាគីអំពីលទ្ធភាពកែប្រែបទចោទ (ដោយគ្មានការបញ្ជាក់ផ្សេងទៀត) ដោយស្នើឱ្យភាគីដាក់សារណា[141] ប៉ុន្តែ តុលាការកំពូលមិនបានយោងដល់សារណាទាំងនេះទេ។ ក្រោយមកទៀត ការកែប្រែតែមួយគត់ យោងតាមវិធាន ១១០(២) នៃវិធានផ្ទៃក្នុង គឺការកែប្រែគួរឱ្យភ្ញាក់ផ្អើល ពីបទឧក្រិដ្ឋសម្លាប់រង្គាលទៅជាបទមនុស្សឃាតដោយចេតនាប្រយោល នៅដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន[142]។

៩៨. ការកែប្រែបទចោទដោយស្ងៀមស្ងាត់ ក្នុងអំឡុងពេលពិភាក្សាសម្រេច ដោយគ្មានការជូនដំណឹង និងដោយមិនផ្តល់ឱកាសឱ្យមេធាវីការពារក្តីបានពិភាក្សាដេញដោលចំពោះមុខ គឺជាអំពើខុសច្បាប់ ពីព្រោះធាតុផ្សំថ្មីត្រូវបានបន្ថែម (ចេតនាប្រយោលមិនស្ថិតក្នុងធាតុផ្សំនៃបទសម្លាប់រង្គាលនោះទេ ហើយក៏មិនមែនជាធាតុផ្សំពាក់ព័ន្ធនៃបទចោទពីដំបូងនោះដែរ)។

៩៩. ជាពិសេស ការកែប្រែបទចោទត្រូវបានធ្វើឡើងក្នុងលក្ខណៈឆ្លៀតឱកាស។ ដូចតុលាការកំពូលបានលើកឡើង បទឧក្រិដ្ឋមនុស្សឃាតមិនត្រូវបានចោទប្រកាន់លើជនជាប់ចោទ សម្រាប់ដំណាក់កាលទីពីរនៃការជម្លៀសប្រជាជនឡើយ[143]។ ផ្ទុយទៅវិញ ជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទសម្លាប់រង្គាល និងបទមនុស្សឃាត សម្រាប់ដំណាក់កាលទីមួយនៃការជម្លៀសប្រជាជន[144]។ ដូច្នេះ ពេលតុលាការកំពូលគ្មានជម្រើសអ្វីផ្សេងក្រៅពីច្រានចោលការផ្តន្ទាទោសពីបទសម្លាប់រង្គាល

---

[140] សេចក្តីសន្និដ្ឋាន **F30/5** កថាខណ្ឌ ៣៣។

[141] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១១។

[142] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៦១-៥៦២។

[143] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៦២ និង ជើងទំព័រ ១៤២៨។

[144] ដីកាដំណោះស្រាយ ឯកសារ **D425** កថាខណ្ឌ ១៣៧៣ និង ១៣៨១។

សម្រាប់ដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ ដោយសារតែគ្មានធាតុផ្សំជាដុំកំភួន និងចេតនាផ្ទាល់[145] ការស្លាប់នៅដំណាក់កាលទីមួយត្រូវបានទទួលស្គាល់ដោយការតម្កល់ការផ្តន្ទាទោសពីបទមនុស្សឃាតដោយចេតនាប្រយោល។ ប៉ុន្តែ ការស្លាប់នៅដំណាក់កាលទីពីរមិនអាចធ្វើបែបនេះបានឡើយ ហើយបើអាចធ្វើបាន ទាល់តែកែប្រែបទចោទជាបទមនុស្សឃាតដោយចេតនាប្រយោល។

១០០. លើសពីនេះទៀត តុលាការកំពូលបានប្រើប្រាស់ការកែប្រែបទចោទនេះ ដើម្បីកែប្រែទម្រង់នៃការទទួលខុសត្រូវ ក្នុងលក្ខណៈប្រយោល ដោយមិនបង្ហាញឱ្យដឹងទាល់តែសោះ។ ជាក់ស្តែង ដើម្បីបញ្ជាក់មូលហេតុនៃការមិនពិនិត្យលើមូលដ្ឋានបណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងក្រៅពីសហឧក្រិដ្ឋកម្មរួម តុលាការកំពូលបានប្រកាសថា៖

> "អង្គជំនុំជម្រះតុលាការកំពូល**រម្លឹក**ថា អង្គជំនុំជម្រះបាន**តម្កល់**ការទទួលខុសត្រូវរបស់ជនជាប់ចោទដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទាក់ទងទៅនឹងអំពើមនុស្សឃាត អំពើអមនុស្សធម៌ផ្សេងទៀត និងអំពើធ្វើទុក្ខបុកម្នេញពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ រួមទាំងអំពើអមនុស្សធម៌ផ្សេងទៀត និងអំពើមនុស្សឃាតទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ"[146]។

១០១. ប៉ុន្តែ ថ្វីត្បិតតែអំពើមនុស្សឃាតនៅដំណាក់កាលទីមួយត្រូវបានចោទប្រកាន់ពីដំបូង ក្នុងក្របខ័ណ្ឌសហឧក្រិដ្ឋកម្មរួម ក៏វាមិនមែនជាករណីនៃការស្លាប់នៅដំណាក់កាលទីពីរដែរ ដែលត្រូវបានចោទប្រកាន់ពីដំបូង ក្នុងបទសម្លាប់រង្គាលតែមួយគត់ តាមរយៈទម្រង់នៃការទទួលខុសត្រូវប្រយោល គឺមិនមែនតាមរយៈសហឧក្រិដ្ឋកម្មរួមទេ។ ដូច្នេះ លោក ខៀវ សំផន មិនត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទាំងនេះទេ (ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ទោះបីជាត្រូវបានកំណត់ថាជាការសម្លាប់រង្គាល ឬការធ្វើមនុស្សឃាតក៏ដោយ។ គាត់ក៏មិនត្រូវបានផ្តន្ទាទោសនៅសាលាដំបូង ពីបទប្រព្រឹត្តអំពើទាំងនេះ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែរ។ គាត់ទើបតែត្រូវបានផ្តន្ទាទោសបែបនេះ ជាលើកទីមួយ នៅតុលាការកំពូល។ តាមពិត "ការរម្លឹក" អំពី "ការតម្កល់" ការដាក់ពិរុទ្ធភាព ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ទាក់ទងនឹងអំពើមនុស្សឃាតនៅដំណាក់កាលទីពីរ

---

[145] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៤១ (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៧-៥៦០ (ដំណាក់កាលទី២) ។

[146] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០៩៩ (យើងជាអ្នកដាក់អក្សរដិត)។

គ្រាន់តែជាល្បិច ដើម្បីបិទបាំងការកែប្រែទម្រង់នៃការទទួលខុសត្រូវ ដែលបានគ្រោងឡើងនៅមុនពេលបើកសវនាការលើបណ្តឹងសាទុក្ខបន្តិចតែប៉ុណ្ណោះ[147]។

១០២. ម្យ៉ាងវិញទៀត តុលាការកំពូលបានស្វែងរកការពារខ្លួនមួយទៀតដើម្បីធ្វើការកែប្រែបទចោទដោយប្រយោលដែលត្រូវបានហាមឃាត់ គឺឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ក្នុងអំឡុងដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន។ តុលាការកំពូលគ្រាន់តែបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រនៃសាលដីកាថា៖

> "អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឲ្យឃើញពីភាពខុសគ្នា ពាក់ព័ន្ធទៅនឹងបញ្ហានេះ រវាងអំពើអមនុស្សធម៌ផ្សេងទៀតនៃការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដែលអង្គជំនុំជម្រះបានរកឃើញថាស្ថិតក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់១ ជាមួយនឹងអំពើអមនុស្សធម៌ផ្សេងទៀតនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ដែលអង្គជំនុំជម្រះបានរកឃើញថា ពុំស្ថិតក្នុងសហឧក្រិដ្ឋកម្មរួមនេះ។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវទាក់ទងនឹងចំណុចទីពីរនេះ ដោយសារបានរៀបចំផែនការ ជាដើម។ ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងទៀត (សូមមើលខាងលើ កថាខណ្ឌ ៥៧២ ជាអាទិ៍) អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបង្ហាញឲ្យឃើញពីភាពខុសគ្នានេះពុំមានភាពចាំបាច់ឡើយ។ ផ្ទុយទៅវិញ ការទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀត គប្បីបានផ្អែកលើតែការទទួលខុសត្រូវ ក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់ ១ ប៉ុណ្ណោះ"[148]។

[147] ទោះជាយ៉ាងណា វាមិនមែនជាកំហុសឡើយ ពីព្រោះថាតុលាការកំពូល នៅក្នុងកំណត់សម្គាល់ជើងទំព័រ បញ្ជាក់ថាបទសម្លាប់រង្គាលពុំត្រូវបានបង្ហាញឱ្យឃើញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយបទមនុស្សឃាតក៏ពុំត្រូវបានស្រូបបញ្ចូលទៅក្នុងបទនេះបន្តទៅទៀតដែរ ហើយការទទួលខុសត្រូវមានអត្ថិភាពដោយផ្អែលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ I (សាលដីកា ០០២/០១ ឯកសារ **F36** ជើងទំព័រ ២៩៧៥ នៃកថាខណ្ឌ ១០៩៩)។ តុលាការកំពូលមិនមានថ្លែងប្រតិកម្មអ្វីឡើយ ហើយប្រុងប្រយ័ត្នមិនប្រតិកម្មអ្វីដែរចំពោះការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

[148] សាលដីកា ០០២/០១ ឯកសារ **F36** ជើងទំព័រ ២៩៧៤ (នៃកថាខណ្ឌ ១០៩៧) ។

១០៣. តុលាការកំពូលបានបន្ទោសអង្គជំនុំជម្រះថា បានផ្តល់និយមន័យច្បាប់ជាក់លាក់ហួសសម័យ ដល់ឧក្រិដ្ឋកម្ម និងបានពិនិត្យឧក្រិដ្ឋកម្មទាំងនេះដាច់ដោយឡែកពីគ្នា ផ្អែកលើនិយមន័យទាំងនេះ[149]។ ប៉ុន្តែ ទោះបីជាអង្គហេតុទាំងនេះត្រូវបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការផ្លាស់ទីលំនៅ/ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ/ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំក៏ដោយ ក៏អង្គជំនុំជម្រះត្រូវពិនិត្យដាច់ដោយឡែកពីគ្នា ពីព្រោះវាជាអង្គហេតុបីឃ្លាតដាច់ដោយឡែកពីគ្នា យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ[150]។ អង្គជំនុំជម្រះត្រូវធ្វើបែបនេះ ពីព្រោះក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ មានតែអង្គហេតុដែលត្រូវបានកំណត់ពីដំបូងថាជាអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំប៉ុណ្ណោះ ដែលត្រូវបានចោទប្រកាន់ក្នុងទម្រង់នៃការទទួលខុសត្រូវប្រយោលតែមួយគត់ គឺមិនមែនក្នុងសហឧក្រិដ្ឋកម្មរួមទេ។

១០៤. ទោះបីជាឧក្រិដ្ឋកម្មត្រូវបានកំណត់និយមន័យច្បាប់យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចប្រកាសពិរុទ្ធភាព តាមរយៈសហឧក្រិដ្ឋកម្មរួម ចំពោះអង្គហេតុទាំងនេះ ដោយមិនឆ្លងកាត់ដំណើរការកែប្រែទម្រង់នៃការទទួលខុសត្រូវបានឡើយ។ អង្គជំនុំជម្រះមិនបានធ្វើបែបនេះទេ។ ដូច្នេះ នៅទីនេះទៀត "ការតម្កល់"[151] ដោយតុលាការកំពូល នូវការប្រកាសពិរុទ្ធភាព ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ចំពោះអំពើអមនុស្សធម៌ផ្សេងទៀត នៅដំណាក់កាលទីពីរ តាមពិត គឺជាការប្រកាសពិរុទ្ធភាពលើកទីមួយ នៅដំណាក់កាលបណ្តឹងសាទុក្ខ ចំពោះអង្គហេតុដែលត្រូវបានកំណត់ពីដំបូងថាជាអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។

---

[149] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៧២ និង កថាខណ្ឌបន្តបន្ទាប់ (និងជាពិសេស កថាខណ្ឌ ៥៨៩ និង ៥៩០)។ សូមមើលផងដែរ កថាខណ្ឌ ៦៥១ ជាពិសេសពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំ នៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ យោងទៅជើងទំព័រ ១៦៩៣ នៅក្នុងកថាខណ្ឌ ៥៨៩។

[150] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៤៩-១៤៥០ (ជនរងគ្រោះត្រូវបានបង្ខំឱ្យចាកចេញពីទីលំនៅស្របច្បាប់របស់ខ្លួន) កថាខណ្ឌ ១៤៣៦ (ប្រជាជនត្រូវបានបង្ខិតបង្ខំឱ្យធ្វើការចាកចេញពីលំនៅដ្ឋានរបស់ខ្លួនជាប្រញាប់ ដោយគ្មានឱកាសត្រៀមរៀបចំរបស់របរសម្ភារៈធ្វើដំណើរ ដោយមិនមានអាហារ និងទឹកទទួលទានគ្រប់គ្រាន់ គ្មានជំនួយវេជ្ជសាស្ត្រ នៅក្នុងលក្ខខណ្ឌនៃការដឹកជញ្ជូន និងជម្រកគ្មានមនុស្សធម៌) កថាខណ្ឌ ១៤៧១ (ការចាប់ខ្លួន ការឃុំខ្លួន ឬ ការចាប់ពង្រត់នូវសាច់ញាតិរបស់ពួកគេ ឬអ្នកដទៃ ដោយមិនផ្តល់ឱ្យពួកគេនូវព័ត៌មានអំពីជោគវាសនារបស់បុគ្គលទាំងនោះ)។ ម្យ៉ាងទៀត តុលាការកំពូលក៏បានពិនិត្យដាច់ដោយឡែកពីគ្នានូវ "សេចក្តីសង្កេតពាក់ព័ន្ធនឹងការបាត់ខ្លួនប្រជាជនជម្លៀស" ៖ សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៤៧-៦៥៣។

[151] សាលដីកា ០០២/០១ ឯកសារ **F36** កថាខណ្ឌ ១០៩៩។

១០៥. ដូច្នេះ តាមរយៈមធ្យោបាយលាក់បំពួនវៀចវេរ និងភាន់ច្រឡំច្បាស់ក្រឡែត តុលាការកំពូលបាន ដាក់បញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលខ្លួនបានសម្រេចតម្កល់ការ ប្រកាសពិរុទ្ធភាព ឬសម្រេចប្រកាសពិរុទ្ធភាព ដើម្បីជួយឃើតយោងដល់ការផ្តន្ទាទោស ចំពោះការ ស្លាប់[152]។ កង្វះតម្លាភាពរបស់តុលាការកំពូល និងវិធីសាស្ត្ររំលោភលើសិទ្ធិរបស់មេធាវីការពារក្តី ហួសពីការសង្ស័យទៅទៀត។ ក្នុងបរិបទនេះ អន្តរាគមន៍របស់តុលាការកំពូល ដើម្បីពង្រីកគោល បំណងឧក្រិដ្ឋរួម និងការទទួលខុសត្រូវ សំដៅធានាបាននូវការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់ មួយជីវិត គឺជាលទ្ធផលកើតចេញពីការលម្អៀងយ៉ាងពិតប្រាកដ។

១០៦. ជាក់ស្តែង ទោះបីជាមានការប្រកាសឲ្យរួចផុតពីបទចោទខ្លះក៏ដោយ ក៏តុលាការកំពូលបានតម្កល់ ការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយបន្ថែម "ការតម្កល់" ការដាក់ពិរុទ្ធភាពពីបទ មនុស្សឃាត "តួនាទីរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម" "ការខ្វះការយកចិត្តទុកដាក់ ទាំងស្រុង" លើជោគវាសនារបស់ប្រជាជន "ការដែលបទឧក្រិដ្ឋនេះពុំមែនជាហេតុការណ៍ដាច់ ដោយឡែក" និង "តួនាទីសំខាន់" របស់ជនជាប់ចោទ[153]។

១០៧. តុលាការកំពូលមិនអាចធ្វើបែបនេះ ដោយមិនរំលោភលើគោលការណ៍នីត្យានុកូលភាព និងដាក់ បញ្ចូលនូវចេតនាប្រយោល ក្នុងនិយមន័យនៃអំពើមនុស្សឃាត និងសហឧក្រិដ្ឋកម្មរួម ទម្រង់១ និង ដោយមិនកែប្រែបទចោទ ពីបទឧក្រិដ្ឋសម្លាប់រង្គាលទៅជាបទមនុស្សឃាតដោយចេតនាប្រយោល និងកែប្រែទម្រង់នៃការទទួលខុសត្រូវទៅជាការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម បានទេ។

១០៨. ក្នុងសំណុំរឿង 00២/0២ ថ្វីត្បិតតែអង្គជំនុំជម្រះមិនបានអនុវត្តតាមតុលាការកំពូល ក្នុងការកំណត់ និយមន័យនៃសហឧក្រិដ្ឋកម្មរួម និងមិនបានកែប្រែទម្រង់នៃការទទួលខុសត្រូវប្រយោលទៅជាការ

---

[152] តុលាការកំពូលបានដកចេញការសម្រេចដាក់ពិរុទ្ធភាពចំពោះបទល្មើសទី៤ ដែលបានលើកឡើងនៅខាងលើ នៅក្នុង កថាខណ្ឌ ៩៤ គឺបទល្មើសធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ នៅទួលពោធិជ្រៃ, ដោយហេតុផលថានយោបាយនៃវិធានការ ប្រឆាំងនឹងក្រុមមនុស្សជាក់លាក់ មិនបានកំណត់បានត្រឹមត្រូវ (សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ១០៩១, ១១០៤ និង ផ្នែកសម្រេចសេចក្តី)។

[153] សាលដីកា 00២/0១ ឯកសារ **F36** កថាខណ្ឌ ១១២0។

ប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួមក៏ដោយ ក៏អង្គជំនុំជម្រះបានដកស្រង់និយមន័យនៃអំពើមនុស្សឃាត និងបានកែប្រែបទឧក្រិដ្ឋសម្លាប់រង្គាលទៅជាបទមនុស្សឃាតដោយចេតនាប្រយោល[154]។

១០៩. ទោះជាយ៉ាងណាក៏ដោយ នៅចំពោះមុខតុលាការកំពូលដែលមានសមាសភាពចៅក្រមប្រាំមួយរូប (ក្នុងចំណោមប្រាំពីររូប) ដែលបានសម្រេចសេចក្តីក្នុងសំណុំរឿង 00២/0១ ម្តងរួចមកហើយ និងធ្លាប់មានភាពលម្អៀងលើបញ្ហាទាំងនេះដែលចោទឡើងសាជាថ្មីម្តងទៀត លោក ខៀវ សំផន ឥតសំណាងទាល់តែសោះ ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខលើសំណុំរឿង 00២/0២។

## ៣.៤. ការប្រកាន់ខ្ជាប់ភាពលម្អៀង តាំងពីពេលប្រកាសសាលក្រមលើសំណុំរឿង 00២/0២

១១០. ប្រសិនបើគ្មានការចាត់តាំងចៅក្រមថ្មីទេ ភាពអភ័ព្វរបស់លោក ខៀវ សំផន នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខលើសំណុំរឿង 00២/0២ រឹតតែមានភាពខ្លាំងក្លាទៅទៀត ដោយសាររបៀបនៃការចេញសេចក្តីសម្រេចរបស់តុលាការកំពូល ចាប់តាំងពីពេលប្រកាសសាលក្រម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មក។

១១១. ជាដំបូង ពេលមេធាវីការពារក្តីស្នើសុំឲ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុមិនគោរពតាមបទប្បញ្ញត្តិជាក់លាក់ និងច្បាស់លាស់បំផុតនៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងទម្រង់ការនៃសាលក្រម[155] តុលាការកំពូលបានគេចវេះពីការលំបាក ដោយប្រកាសមិនទទួលយកបណ្តឹងសាទុក្ខ តាមរយៈការបំភ្លៃកម្មវត្ថុនៃបណ្តឹងសាទុក្ខនោះ[156]។ ជាក់ស្តែង ខណៈដែលមេធាវីការពារក្តីប្តឹងសាទុក្ខច្បាស់

[154] ចំណុចដែលកំពុងតែរងការជំទាស់នៅក្នុងបណ្តឹងសាទុក្ខ សូមមើលឧបសម្ព័ន្ធ ទី១ (ការកែប្រែបទចោទ), ទី៧ (មនុស្សឃាត) និងទី៨-៩ ស្តីពីការប្រើប្រាស់ការកែប្រែបទចោទ។

[155] បណ្តឹងសាទុក្ខភ្លាមៗ **E463/1** ។ ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** ("ការឆ្លើយតប **E463/1/2/1**")។

[156] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារ **E463/1/3**។

ក្រឡែតប្រឆាំងនឹង**ផ្នែកសម្រេចសេចក្តី**នៃសាលក្រម[157] តុលាការកំពូលបែរជាសម្រេច ដូចជាមេធាវីការពារក្តីប្តឹងសាទុក្ខប្រឆាំងនឹង**សេចក្តីសង្ខេប**នៃសាលក្រមទៅវិញ[158]។

១១២. បន្ទាប់មកទៀត នៅពេលមេធាវីការពារក្តីស្នើសុំធ្វើមោឃភាពសេចក្តីសម្រេចនេះ ដោយហេតុថា ចៅក្រមបម្រុងមិនត្រូវបានតែងតាំងជាផ្លូវការជាចៅក្រមពេញសិទ្ធិ ពេលធ្វើសេចក្តីសម្រេចនោះ[159] តុលាការកំពូលមិនបានជូនដំណឹងអំពីសំណើនេះទេ អស់រយៈពេលជាងបីខែ ខណៈដែលសំណើនេះគួរណាតែត្រូវដាក់ចូលក្នុងសំណុំរឿង "ភ្លាម"[160]។ នេះមិនមែនជាការភ្លេចភ្លាំងឡើយ ពីព្រោះមេធាវីការពារក្តីបានរម្លឹកអំពីអត្ថិភាពនៃសំណើនេះបួនដងរួចមកហើយ ក្នុងសារណាដែលដាក់នាពេលក្រោយៗមកទៀត[161]។

១១៣. ប្រាំខែក្រោយពីការដាក់សំណើទើសមុខទើសមាត់នេះ តុលាការកំពូលបានសម្រេចថា សំណើនេះគ្មានមូលដ្ឋាន ដោយបានផ្តល់ "សំអាងហេតុ" គួរឱ្យស្រឡាំងកាំង[162]។ ជាក់ស្តែង តុលាការកំពូលយល់ឃើញថា មេធាវីការពារក្តីបំភ្លៃកាលប្បវត្តិ ខណៈដែលតុលាការកំពូលបានផ្តល់កាលប្បវត្តិដូចគ្នាបេះបិទ[163] និងបានបង្ហាញឱ្យឃើញរឹតតែច្បាស់អំពីការធ្វើការពិភាក្សាសម្រេចជាមួយចៅក្រម

[157] ជាពិសេស ៖ បណ្តឹងសាទុក្ខភ្លាមៗ **E463/1** កថាខណ្ឌ ២-៣ (និងជើងទំព័រ ដែលយោងតែទៅផ្នែកសម្រេចសេចក្តីប៉ុណ្ណោះ) ១១, ១៧។ ការឆ្លើយតប **E463/1/2/1** កថាខណ្ឌ ១៧-២២។ ក្នុងពេលពីលើក ដែលមេធាវីការពារក្តីបានរំឭកពីសេចក្តីសង្ខេប មេធាវីការពារក្តីក៏បានរំឭកផងដែរថាផ្នែកសម្រេចសេចក្តីមិនអាចយកជាការបានឡើយ ដោយហេតុថាមិនមានអានុភាពផ្លូវច្បាប់មួយឡើយ (បណ្តឹងសាទុក្ខភ្លាមៗ ឯកសារ **E463/1** កថាខណ្ឌ ៦១។ ការឆ្លើយតប **E463/1/2/1** កថាខណ្ឌ ៥២) ។

[158] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារ **E463/1/3** ចំណងជើង និង កថាខណ្ឌ ៦, ១២, ១៨។

[159] សំណើសុំធ្វើមោឃភាព ឯកសារ **E463/1/4**។

[160] សូមមើលខាងលើ កថាខណ្ឌ ៤ និង ជើងទំព័រ ១២ ។ វិធាន ១០៨.៦ នៃវិធានផ្ទៃក្នុង ។

[161] សំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ឯកសារ **F39/1.1** កថាខណ្ឌ ២ និង ជើងទំព័រ ៥។ ការឆ្លើយតប និងចម្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញាស្តីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F41/1** កថាខណ្ឌ ២ និង ជើងទំព័រ ៥។ ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F42/1** កថាខណ្ឌ ២ និង ជើងទំព័រ ៥។ សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ ឯកសារ **E465/4/1** កថាខណ្ឌ ៣ និង ជើងទំព័រ ៦។

[162] សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព ឯកសារ **E465/1/5**។

[163] ប្រៀបធៀប ៖ សំណើសុំធ្វើមោឃភាព ឯកសារ **E463/1/4** កថាខណ្ឌ ៧-៨ និង សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព

បម្រុង មុនពេលប្រកាសជាផ្លូវការជាចៅក្រមពេញសិទ្ធិ[164]។ ទោះជាតុលាការកំពូលបានព្យាយាមបញ្ជាក់ថា ចៅក្រមបម្រុងបានទទួលការតែងតែងតាមផ្លូវច្បាប់ និងបានស្បថចូលកាន់តំណែងជាចៅក្រមតុលាការកំពូល មុនពេលចេញសេចក្តីសម្រេចនោះក៏ដោយ[165] ក៏តុលាការកំពូលមិនបាននិយាយអ្វីទាល់តែសោះ ពាក់ព័ន្ធនឹងការប្រកាសជាផ្លូវការឲ្យចូលកាន់តំណែងជាចៅក្រមពេញសិទ្ធិ ដោយសារតែតុលាការមានចេតនាគេចវេះពីបញ្ហា ឬតុលាការកំពូលយល់ឃើញថាការតែងតាំងជាចៅក្រមពេញសិទ្ធិមិនចាំបាច់ត្រូវប្រកាសជាផ្លូវការ ដើម្បីឲ្យមានសុពលភាពនោះទេ។ ទោះជាយ៉ាងណាក៏ដោយ កង្វះតម្លាភាពជាញឹកញាប់ និងគួរឲ្យសង្ស័យរបស់តុលាការកំពូល មិនអាចទទួលពីទំនុកចិត្តពីជនជាប់ចោទបានឡើយ។

## សេចក្តីសន្និដ្ឋាន

១១៤. ធាតុផ្សំអង្គហេតុ និងអង្គច្បាប់ ដែលបានអធិប្បាយខាងលើ ចោទជាបញ្ហាដល់ភាពអនាគតិរបស់ចៅក្រមរងបណ្តឹងជិតចិត្ត។ ចំពោះអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ និងទទួលបានព័ត៌មានគ្រប់គ្រាន់ ការលម្អៀង និងយ៉ាងហោចណាស់ ការស្តែងចេញនូវភាពលម្អៀង ពិតជាមានអត្ថិភាពមិនអាចប្រកែកបាន។ ការឈានទៅដល់ការសន្និដ្ឋានមួយផ្សេងទៀតមានន័យស្មើនឹងការជំទាស់តវ៉ានឹងការដែលថាតុលាការគឺជាមនុស្ស។ វាមិនអាចទៅរួចទេដែលចៅក្រមមិនពិចារណាដល់សេចក្តីសន្និដ្ឋាន ដែលខ្លួនធ្លាប់ធ្វើម្តងរួចមកហើយ ដោយផ្អែកលើអង្គហេតុដដែល និងពាក់ព័ន្ធនឹងជនជាប់ចោទដដែល។ នេះជាការប្រថុយប្រថានដែលត្រូវចៀសវាង នៅដំណាក់កាលដ៏សំខាន់នេះនៃកិច្ចដំណើរការនីតិវិធី។ បញ្ហាប្រឈមនៃគោលការណ៍ និងកេរដំណែលតុលាការនៃ អ.វ.ត.ក មានទំហំធំធេងណាស់។

ឯកសារ E465/1/5 កថាខណ្ឌ ៥។

[164] ប្រៀបធៀប ៖ សំណើសុំធ្វើមោឃភាព ឯកសារ E463/1/4 កថាខណ្ឌ ៨ និង ជើងទំព័រ ១៥ និង សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព ឯកសារ E465/1/5 កថាខណ្ឌ ៦ (បញ្ហាស្ថិតនៅត្រង់ថាការសម្រេចបានប្រព្រឹត្តទៅ ហើយសេចក្តីសម្រេចមុនដំណើរការបញ្ចប់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលប្រើប្រាស់ពេលវេលាយូរ) ។

[165] សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព ឯកសារ E465/1/5 កថាខណ្ឌ ៤។

១១៥. សិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២/០២ កំពុងចោទជាបញ្ហា។ ផលប្រយោជន៍យុត្តិធម៌ត្រូវមានប្រៀបលើសគេ។ ការប្ដឹងជំទាស់ចៅក្រមនឹងមិនបង្កឲ្យមានភាពយឺតយ៉ាវដល់កិច្ចដំណើរការនីតិវិធីឡើយ ពីព្រោះវាមិនមានអានុភាពផ្អាកដំណើរការនីតិវិធីទេ ហើយកាលកំណត់បណ្ដឹងសាទុក្ខនៅតែអនុវត្តដដែល។ ការប្ដឹងជំទាស់នេះអាចឲ្យគោរពសច្ចធារណ៍និរទោស ក្នុងក្របខ័ណ្ឌនៃសិទ្ធិប្ដឹងសាទុក្ខប្រកបដោយប្រសិទ្ធភាពរបស់លោក ខៀវ សំផន ដែលជាលក្ខខណ្ឌចាំបាច់នៃសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។

១១៦. **អាស្រ័យហេតុនេះ** លើកលែងតែចៅក្រមរងបណ្ដឹងជំទាស់លាលែងដោយស្ម័គ្រចិត្ត យោងតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង មេធាវីការពារក្ដីស្នើសុំតុលាការកំពូលមេត្តា៖

- **បើក**សវនាការពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ
- **ដកហូតសិទ្ធិ**ពីចៅក្រមទាំងប្រាំមួយរូប យោងតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង។

| | | |
|---|---|---|
| មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |